រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# សមិទ្ធផល និងទិសដៅ

## នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## រយៈពេល ៥ ឆ្នាំ

សេចក្តីព្រាង


រៀបចំនិងសម្របសម្រួលដោយ

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារ

កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



ខែមេសា ឆ្នាំ២០១៨

# បុព្វកថា

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព, ឯកភាពទឹកដី, ឯកភាពជាតិ, ស្ថិរភាពនយោបាយរឹងមាំ, ការប្រកាន់ភ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ, នីតិរដ្ឋ និងការគោរពសិទ្ធមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញនិងច្បាប់, រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា បានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ។ ចាប់តាំងឆ្នាំ២០១៣ មក រាជរដ្ឋាភិបាលបានបន្តជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី, មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យ រួមទាំងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, រដ្ឋបាលសាធារណៈ និងវិមជ្ឈការ និងវិសហមជ្ឈការ ក្នុងគោលដៅបង្កើន និងកែលម្អការផ្តល់គុណភាពសេវាសាធារណៈ ប្រកបដោយគុណភាព, ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ។

សម្រាប់រយៈពេល ៥ ឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលសម្រេចបានកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំក្នុងរង្វង់ ៧,០% ប្រកបដោយបរិយាប័ន្ន និងសមធម៌។ ក្នុងន័យនេះ កម្ពុជាសម្រេចបាននូវបង្គោលគោរចរជាប្រវត្តិសាស្ត្រ គឺការឆ្លងពីប្រទេសមានចំណូលមធ្យមកម្រិតទាបជាផ្លូវការនៅឆ្នាំ២០១៥ ព្រមទាំងត្រូវបានចាត់ទុកថាជា “ខ្លាសេដ្ឋកិច្ចនៅអាស៊ី” នៅឆ្នាំ២០១៦ ហើយភាពគ្មានការងារធ្វើស្ថិតក្នុងអត្រា ០,៣%, ភាពក្រីក្រតោកយ៉ាកត្រូវបានលុបបំបាត់ចោលទាំងស្រុងក្នុងឆ្នាំ២០១៧ និងប្រាក់ចំណូលក្នុងមនុស្សម្នាក់កើនពី ១ ០៤២ ដុល្លារអាមេរិកក្នុងឆ្នាំ២០១៣ ដល់ប្រមាណ ១ ៤២៧ ដុល្លារអាមេរិកក្នុងឆ្នាំ២០១៧ ។

ចំណែកឯ ក្នុងក្របខ័ណ្ឌកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលនៅតែមានភាពរឹងមាំដែលចំណូលមានការកើនឡើងក្នុងចន្លោះ ១៥%-២០% ក្នុងមួយឆ្នាំ ក្នុងរយៈពេល ៥ឆ្នាំ ចុងក្រោយ ហើយចំណូលចន្ទថវិកាជាតិបានកើនឡើងពីប្រមាណ ១៥,០៦% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០១៣ ដល់ ១៩,៦៤% ក្នុងឆ្នាំ ២០១៧ ពោលគឺកើនឡើងជិតពីដង ឬប្រមាណជា ៤,៥៨ ពិន្ទុភាគរយនៃ ផ.ស.ស.។ រីឯ ថវិកាចំណាយបានកើនឡើងប្រមាណ ១,៨ ដង ហើយការវិភាជត្រូវបានគិតគូលើវិស័យអាទិភាពសំខាន់ៗ និងការអនុវត្តថវិកាផ្នែកចំណាយក៏កាន់តែមានប្រសិទ្ធភាព ទាំងកម្រិតវិភាជន៍ និងកម្រិតប្រតិបត្តិការ ។

ជារួម សមិទ្ធផលរយៈពេល ៥ឆ្នាំ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្លុះបញ្ចាំងថា សមាធាតុគន្លឹះទាំង ៤ បាននិងកំពុងរៀបចំ និងពង្រឹងការអនុវត្ត រួមមាន ជាអាទិ៍ ÷ ការរៀបចំប្រព័ន្ធ, ការរៀបចំក្របខ័ណ្ឌគតិយុត្ត, ការរៀបចំយន្តការ និងការកសាងធនធានមនុស្សលើវិស័យហិរញ្ញវត្ថុសាធារណៈ ។ ក្នុងន័យនេះ គ.ហ.ស. មានសុទិដ្ឋិនិយម និងវាយតម្លៃជារួមថា÷ (១).ភាពជឿទុកចិត្តនៃថវិកានៅតែរក្សាបានជាសារវន្ត, (២).ប្រព័ន្ធគណនេយ្យភាពបាននិងកំពុងកសាងតាមរយៈការដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS ដំណាក់កាលទី២ ជាមួយនឹងភាពប្រុងប្រយ័ត្នខ្ពស់, (៣).ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធីជាមូលដ្ឋានគ្រឹះសម្រាប់រៀបចំ និងកំណត់ការផ្លាស់ប្តូរប្រព័ន្ធថវិកាកម្ពុជា, (៤).ការរៀបចំ និងដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ ជាសមាសធាតុសំខាន់សម្រាប់កំណត់ទិសដៅនៃគណនេយ្យភាពសមិទ្ធកម្ម និង (៥).ការរៀបចំប្រព័ន្ធលើកទឹកចិត្ត នឹងជំរុញការធ្វើស្ថាប័ននីយកម្មឱ្យស្របតាមទិសដៅនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

តាងនាមឱ្យ គ.ហ.ស. ខ្ញុំសូមសម្តែងកតញ្ញុតាធមិដ៏ជ្រាលជ្រៅចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ជាអគ្គមគ្គុទេសក៍ និងស្ថាបនិកដ៏ឆ្នើមលើការងារកែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា ដែល **សម្តេចតេជោនាយករដ្ឋមន្ត្រី** តែងតែងគាំទ្រផ្នែកនយោបាយ និងផ្តល់អនុសាសន៍សំដៅតម្រង់ទិសកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីឱ្យការអនុវត្តសម្រេចបានដោយជោគជ័យ និងចីរភាព ។ ទន្ទឹមនេះ ខ្ញុំសូមធ្វើការវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានផ្តល់កិច្ចសហការ, ចូលរួម និងខិតខំអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយបុរេសកម្ម, សកម្ម និងអន្តរសកម្ម ។ ជាមួយគ្នានេះ ខ្ញុំសូមអរគុណជាថ្មីម្តងទៀត ចំពោះបណ្តាដៃគូអភិវឌ្ឍន៍នានា ដែលបានប្តេជ្ញាបន្តផ្តល់ការគាំទ្រចាំបាច់, ទាំងជាហិរញ្ញប្បទាន ទាំងជាជំនួយបច្ចេកទេស, ប្រកបដោយសុឆន្ទៈ និងប្រកបដោយចីរភាព ចំពោះការងារកែទម្រង់នេះ ឱ្យសម្រេចបានជោគជ័យតាមការគ្រោងទុក ក្នុងស្មារតីនៃការគោរព និង លើកតម្កើងភាពជាម្ចាស់របស់កម្ពុជា។

ថ្ងៃ ខែ ឆ្នាំ ព.ស.

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាកម្មវិធីកែទម្រង់រយៈពេលវែង ដែលមានចក្ខុវិស័យប្រកបដោយមហិច្ឆតា និងប្រាកដនិយម គឺផ្លាស់ប្តូរប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្ពោះទៅស្តង់ដារអន្តរជាតិ ។ ការផ្លាស់ប្តូរប្រព័ន្ធហិញ្ញវត្ថុសាធារណៈនេះ មានន័យថា ការផ្លាស់ប្រព័ន្ធហិរញ្ញវត្ថុដែលមានលក្ខណៈបែបមជ្ឈការឆ្ពោះទៅប្រព័ន្ធហិរញ្ញវត្ថុបែបវិមជ្ឈការ ។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០០៤ ដោយត្រូវបានបែងចែកចេញជាបួនជំហាន/ដំណាក់កាល រួមមាន ជាអាទិ៍÷

- ដំណាក់កាលទី១ “ភាពជឿទុកចិត្តនៃថវិកា” ពីឆ្នាំ២០០៥-២០០៨;
- ដំណាក់កាលទី២ “គណនេយ្យភាពហិរញ្ញវត្ថុ” ពីឆ្នាំ២០០៩-២០១៥;
- ដំណាក់កាលទី៣ “ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ” ពីឆ្នាំ២០១៦-២០២០;
- ដំណាក់កាលទី៤ “គណនេយ្យភាពសមិទ្ធកម្ម” ពីឆ្នាំ២០២១-២០២៥ ។

ដើម្បីជំរុញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យប្រកបដោយ ជវភាព, ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព, អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(អ.គ.ហ.) បានខិតខំបំពេញមុខងាររបស់ខ្លួនជាឧត្តមសេនាធិការជូន គ.ហ.ស. ទាំងការងារដឹកនាំ, សម្របសម្រួល, គាំទ្រ និងតាមដាន ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាប្រចាំ ។ អាស្រ័យហេតុនេះ អ.គ.ហ. បានរៀបចំរបាយការណ៍សមិទ្ធផលសម្រេចបានរយៈពេល ៥ឆ្នាំ ចាប់ពីឆ្នាំ ២០១៣-២០១៧ ដោយរំលេចទាំងសមិទ្ធផល, បញ្ហាប្រឈម និងទិសដៅធ្វើបន្តរយៈពេល ៥ឆ្នាំ ចាប់ពីឆ្នាំ២០១៨-២០២២ សម្រាប់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ។

សមិទ្ធផលសម្រេចបាននៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា គឺបាននិងកំពុងកសាង និងពង្រឹងព្រ័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ក្នុងន័យនេះ អ.គ.ហ. សូមធ្វើការវាយតម្លៃជារួម ដូចតទៅ÷

១. ថវិកាកាន់តែមានភាពជឿទុកចិត្ត និងបានក្លាយជាកម្លាំងចលករក្នុងការទ្រទ្រង់ និងជំរុញកំណើនសេដ្ឋកិច្ច;

២. បុរេលក្ខណៈសំខាន់ៗត្រូវបានកសាង និងពង្រឹងបន្ថែម ដើម្បីធានាគណនេយ្យភាពហិរញ្ញវត្ថុ;

៣. ក្របខ័ណ្ឌថវិកាកម្មវិធី ត្រូវបានរៀបចំ ពង្រឹង និងពង្រីកការអនុវត្ត ដែលជាឧបករណ៍សំខាន់សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល;

៤. សមត្ថភាពមន្ត្រីនៃក្រសួង ស្ថាប័នក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានពង្រឹង;

៥. ការយល់ដឹង និងការចូលរួមអនុវត្តកម្មវិធីកែទម្រង់កើនឡើងជាលំដាប់ ។

ក្នុងនាម អ.គ.ហ. និងរូបខ្ញុំផ្ទាល់ សូមថ្លែងអំណរគុណជូនឯកឧត្តមបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាន គ.ហ.ស. ដែលផ្តល់អនុសាសន៍ណែនាំដ៏មានតម្លៃ ដើម្បីតម្រង់ទិសដល់ អ.គ.ហ.,ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សំដៅឱ្យការអនុវត្តគោលដៅដែលបានដាក់ចេញក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យសម្រេចបានជោគជ័យ និងចីរភាព ។

ថ្ងៃ ខែ ឆ្នាំ ព.ស.

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**អគ្គលេខាធិការ**

**អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារ**

**កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

# មាតិកានុក្រម


បុព្វកថា .......................................................................i

អារម្ភកថា..................................................................... iii

១.សាវតារ...................................................................... ១

២. គោលបំណង និងគោលដៅ.................................... ៤

៣. សមិទ្ធផលរយៈពេល ៥ ឆ្នាំ (២០១៣-២០១៧) ................. ៥

៤. បញ្ហាប្រឈម ..........................................................៥៥

៥. ទិសដៅរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ......... ៥៦

៥.១. ទិសដៅនៃ PFMRP សម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ .៥៧

៥.២. ទិសដៅនៃ PFMRP សម្រាប់ក្រសួង ស្ថាប័ន.................... ៥៩

៦. សន្និដ្ឋាន .......................................................... ៦០

# សមិទ្ធផល និងទិសដៅ

## នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រយៈពេល ៥ ឆ្នាំ

### ១.សាវតារ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Public Financial Management Reform Program-PFMRP) គឺជាកម្មវិធីកែទម្រង់ស្នូលមួយ នៃកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីពង្រឹងអភិបាលកិច្ច និងទ្រទ្រង់ការអភិវឌ្ឍសេដ្ឋកិច្ច ប្រកបដោយបរិយាប័ន្ន និងសមធម៌ ដូចមានកំណត់ក្នុងយុទ្ធសាស្រ្តចតុកោណ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ។ PFMRP គឺមានចក្ខុវិស័យប្រកបដោយមហិច្ឆិតានិងប្រាកដនិយម ពោលគឺកសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ឱ្យស្របតាមឧត្តមានុវត្តន៍អន្តរជាតិ ដែលជាប្រព័ន្ធផ្តោតលើធាតុចេញ ឬលទ្ធផល និងវិមជ្ឈការ ។

ក្នុងទស្សនវិស័យនេះ PFMRP ត្រូវបានប្រកាសដាក់ឱ្យអនុវត្តនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៤ ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ។ ដើម្បីការអនុវត្ត PFMRP ឱ្យស្របតាមបរិបទការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងសេដ្ឋកិច្ចរបស់កម្ពុជា រាជរដ្ឋាភិបាល ប្រកាន់យកអភិក្រមជាខឿន (Platform Approach) ចំនួនបួន និងត្រូវបានរៀបចំអនុវត្តជាបួន ដំណាក់កាល រួមមាន ជាអាទិ៍ ÷

- ដំណាក់កាលទី១ “ភាពជឿទុកចិត្តនៃថវិកា” ឆ្នាំ២០០៥-២០០៨;

- ដំណាក់កាលទី២ “គណនេយ្យភាពហិរញ្ញវត្ថុ” ឆ្នាំ២០០៩-២០១៥;
- ដំណាក់កាលទី៣ “ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ” ឆ្នាំ ២០១៦-២០២០;
- ដំណាក់កាលទី៤ “គណនេយ្យភាពសមិទ្ធកម្ម” ឆ្នាំ២០២១-២០២៥ ។

ដ្យាក្រាម 1: អភិក្រមជាជំហាន/ ដំណាក់កាលនៃ PFMRP




ទន្ទឹមនេះ ដើម្បីឱ្យការអនុវត្ត PFMRP ទទួលបានជោគជ័យ និងចីរភាព ការចូលរួមរបស់តួអង្គពាក់ព័ន្ធសំខាន់ពិតជាមានសារៈសំខាន់ ដោយក្នុងនោះរួមមាន (១). ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, (២). ក្រសួង ស្ថាប័ន និង (៣).ដៃគូអភិវឌ្ឍន៍គាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស ព្រមទាំងមានការសម្របសម្រួល និងគាំទ្រពី អ.គ.ហ.។ ក្នុងន័យនេះ កសហវ មានតួនាទីតួនាទីនាំមុខ ក្នុងការដឹកនាំការងារកែទម្រង់ និងតួនាទីប្រតិបត្តិគន្លឹះរបស់ក្រសួង ស្ថាប័ន ដែលត្រូវតែបុរេសកម្ម

មានភាពជាម្ចាស់ និងមានការទទួលខុសត្រូវខ្ពស់ ដែលជាកត្តាគន្លឹះកំណត់ជោគជ័យនៃការងារកែទម្រង់នេះ ។

ជាមួយគ្នានេះ លើវិថីនៃការកែទម្រង់ គ្រប់តួអង្គទទួលស្គាល់ពីភាពស្មុគស្មាញ និងការលំបាកជាសត្យានុម័តនានា ដូចប្រសាសន៍របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ថា: ***"គ្មានលទ្ធផលណាដែលបានមក ដោយមិនមានការបង់ថ្លៃនោះទេ, ហើយក៏គ្មានការកែទម្រង់ណា ដែលសម្រេចបានដោយមិនមានការលះបង់នោះដែរ"*** ។ ទោះបីជាយ៉ាងណាក៏ដោយភាពស្មុគស្មាញ និងបញ្ហាប្រឈម ត្រូវបានដោះស្រាយជាបណ្តើរៗ ដោយមិនគ្រាន់តែទទួលបាននូវការគាំទ្រជានយោបាយយ៉ាងពេញទំហឹងពី **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ប៉ុណ្ណោះទេ, ក៏ប៉ុន្តែថែមទាំងទទួលបាននូវការលើកទឹកចិត្ត, ការណែនាំចង្អុលបង្ហាញជាប្រចាំ ។ ក្នុងន័យនេះ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ជា "**អគ្គមេបញ្ជាការនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**" ដ៏ឆ្នើមប្រកបដោយគតិបណ្ឌិត, សេចក្តីក្លាហានក្នុងការងារកកែទម្រង់, និងមានចក្ខុវិស័យវែងឆ្ងាយ ដើម្បីការអភិវឌ្ឍកម្ពុជា ក្នុងបរិការណ៍នៃប្រវត្តិសាស្ត្រស្មុគ្រស្មាញ និងអនាគតប្រកបដោយក្តីសង្ឃឹម ។

អាស្រ័យហេតុនេះ គ.ហ.ស. បានដាក់ចេញជាវិធានការជាច្រើន សំដៅគាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមាន÷

១. ក្របខ័ណ្ឌផែនការសម្មភាពរួម ដំណាក់កាលទី៣ (CAP3) ផ្តោតលើអាទិភាពចំនួន ៣ រួមមាន (១). ពង្រឹងការគ្រប់គ្រង និងអនុវត្តផែនការប្រមូលចំណូល, (២). ពង្រឹងនិងពង្រីកការដាក់ឱ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

សម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) និង (៣). ពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី;

២. ធ្វើការត្រួតពិនិត្យសុខភាព នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាប្រចាំតាមរយៈការប្រើប្រាស់ក្របខ័ណ្ឌគណនេយ្យភាព និងចំណាយសាធារណៈ (PEFA) ដែលមានប្រទេសប្រមាណ ១៥០ នៅលើពិភពលោកប្រើប្រាស់;

៣. រៀបចំ និងអនុវត្តយន្តការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាពរបស់ក្រសួង ស្ថាប័ន ដើម្បីធានានូវប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព;

៤. រៀបចំ និងអនុវត្តយន្តការដោះស្រាយបញ្ហាប្រឈមដែលប្រទាក់ក្រឡាគ្នារវាងការងារកែទម្រង់ទាំងបី រួមមាន ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, រដ្ឋបាលសាធារណៈ និងវិមជ្ឈការ និងវិសហមជ្ឈការ ។

## ២. គោលបំណង និងគោលដៅ

របាយការណ៍សមិទ្ធផល និងទិសដៅបន្តនៃការអនុវត្ត PFMRP រយៈពេល ៥ ឆ្នាំ បង្ហាញនូវសមិទ្ធផលរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ខិតខំអនុវត្តព្រមទាំងកំណត់នូវបញ្ហាប្រឈម និងទិសដៅបន្តរយៈពេល ៥ ឆ្នាំ សម្រាប់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ។ ក្នុងន័យនេះ របាយការណ៍បានគូសបញ្ជាក់នូវភាពគ្រប់ជ្រុងជ្រោយ, ភាពច្បាស់លាស់ និងភាពប្រាកដនិយមរបស់រាជរដ្ឋាភិបាលដើម្បីឈានទៅសម្រេចចក្ខុវិស័យនៃ PFMRP ។

## ៣. សមិទ្ធផលរយៈពេល ៥ ឆ្នាំ (២០១៣-២០១៧)

PFMRP គឺជាកម្មវិធីកែទម្រង់មួយនៃកម្មវិធីកែទម្រង់ស្នូលរបស់រាជរដ្ឋាភិបាល ដែលបានកំណត់ក្នុងយុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៣ និងផែនការយុទ្ធ-សាស្រ្តអភិវឌ្ឍន៍ជាតិ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច, បង្កើតការងារ ធានាសមធម៌ក្នុងសង្គម និងធានាបាននូវប្រសិទ្ធភាព ។ ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ ការកែទម្រង់គឺស្ថិតក្នុងសភាពការណ៍ប្រែប្រួលដ៏ឆាប់រហ័ស ទាំងក្នុង និងក្រៅប្រទេស ឬហៅថាសភាពការណ៍ចល័ត ។ ប្រការនេះ ផ្តល់ឱកាសឱ្យរដ្ឋាភិបាលបន្តការងារកែទម្រង់ផង និងសាកល្បង "ភាពឆ្លើយតបនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ" ផង ជាពិសេស ការឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ថ្មីៗ និងបំណងប្រាថ្នាកើនឡើងរបស់ប្រជាជន ។ លើសពីនេះ ការគ្រប់គ្រងថវិកាជាតិកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ប្រកបដោយវិចារណកម្ម និងតម្លាភាពដែលបានចូលរួមចំណែកលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងកសាងរចនា-សម្ព័ន្ធរូបវន្ត ដែលបានផ្តល់នូវបច្ច័យវិជ្ជមានដល់ការធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាពប្រជាពលរដ្ឋ និងបានរួមចំណែកកាត់បន្ថយភាពក្រីក្របានច្រើនជាង ១% ក្នុងមួយឆ្នាំ ។

សមិទ្ធផលរយៈពេល ៥ ឆ្នាំ ត្រូវបានបង្ហាញក្នុងទិដ្ឋភាពចំនួនពីសមិទ្ធផលក្នុងទិដ្ឋភាពហិរញ្ញវត្ថុសាធារណៈ ដោយលទ្ធផលចុងក្រោយ (Outcomes) និងភាព-ខ្លាំង និងភាពខ្សោយនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រទ្រង់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចមានបញ្ជាក់លម្អិតខាងក្រោម ។

## ៣.១. សមិទ្ធផលក្នុងនិដ្ឋភាពទូទៅ នៃកម្មវិធីកែទម្រង់

### ១. ថវិកាកាន់តែមានភាពជឿទុកចិត្ត និងបានក្លាយជាចលករ ដើម្បីរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងចីរភាពហិរញ្ញវត្ថុសាធារណៈ

- រដ្ឋាភិបាលសម្រេចបានសូចនាករសំខាន់ៗនៃក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចរួមមាន កំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧%, រក្សាបាននូវអតិផរណាទាបក្នុងរង្វង់ ៣%, អត្រាប្តូរប្រាក់ក្នុងរង្វង់ ៤ ០០០ រៀល/ដុល្លារអាមេរិក, ឱនភាពថវិកាទាបនៅក្នុងកម្រិត +/-៥% នៃ ផ.ស.ស.។
- ចំណូលមានការកើនឡើងក្នុងចន្លោះ ១៥%-២០% ក្នុងមួយឆ្នាំក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ ហើយចំណូលចរន្តថវិកាជាតិបានកើនឡើងពីប្រមាណ ១៥,០៦% នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៣ ដល់ ១៩,៦៤% ក្នុងឆ្នាំ២០១៧ (ទិន្នន័យបណ្តោះអាសន្ន) ពោលគឺកើនឡើងជិតពីរដងឬប្រមាណជា ៤,៥៨ ពិន្ទុភាគរយនៃ ផ.ស.ស.។ ជាមួយគ្នានេះ ការអនុវត្តចំណូលកាន់តែខិតជិតគោលដៅ +/-៥% នៃឥណទានកំណត់ក្នុងច្បាប់ ។
- ថវិកាចំណាយបានកើនឡើងប្រមាណ ១,៨ ដង ចាប់ពីឆ្នាំ២០១៣-២០១៧ ហើយការវិភាជត្រូវបានគិតគូលើវិស័យអាទិភាពសំខាន់ៗ និងការអនុវត្តថវិកាផ្នែកចំណាយក៏កាន់តែមានប្រសិទ្ធភាព ទាំងកម្រិតវិភាជន៍ និងកម្រិតប្រតិបត្តិការ ។ ជាមួយគ្នានេះ ការអនុវត្តចំណាយ គឺកាន់តែខិតជិតគោលដៅ +/-៥% នៃឥណទានកំណត់ក្នុងច្បាប់ ។

- អតិរេកថវិកាចរន្តសម្រេចបានក្នុងចន្លោះ ៣,៦% នៃ ផ.ស.ស. ក្នុង ១ ឆ្នាំ និងបានកាត់បន្ថយឱនភាពថវិកាសរុប ពី -៧,០១% (ជាក់ស្ដែង) ក្នុងឆ្នាំ ២០១៣ នៃ ផ.ស.ស មកត្រឹម -៥,៨៤% (ច្បាប់ថវិកា) នៃ ផ.ស.ស.ក្នុងឆ្នាំ ២០១៨ ។
- ការគ្រប់គ្រងសាច់ប្រាក់មានប្រសិទ្ធភាព ដោយគ្មានបំណុលកកស្ទះ ក្នុងនោះ បៀវត្ស និងប្រាក់បំណាច់ផ្សេងៗ របស់មន្ត្រីរាជការ និងបុគ្គលិករដ្ឋ ត្រូវផ្ទេរផ្ទាល់ចូលក្នុងគណនីធនាគារ នៅក្នុងសប្ដាហ៍ទី៤ នៃខែ ។ បន្ថែមពីនេះ និវត្តជនក៏បានទទួលនូវការបង្កើនប្រាក់សោធន និងរបបតាវលិកផ្សេងទៀត ជាបន្តបន្ទាប់ផងដែរ ។
- បំណុលសាធារណៈ ត្រូវបានគ្រប់គ្រងត្រឹមត្រូវ និងអនុវត្តខ្ជាប់ខ្ជួននូវគោលការណ៍គន្លឹះទាំង ៤ ចំណុច រួមមាន (១). ត្រូវខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន, (២). ត្រូវខ្ចីឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់, (៣). ត្រូវខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពកំណើន និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច និង (៤).ត្រូវប្រើប្រាស់ឥណទានទាំងនោះ ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព និងស័ក្ដិសិទ្ធភាពខ្ពស់បំផុត។ ទន្ទឹមនេះ រាជរដ្ឋាភិបាល រក្សាបានកម្រិតអនុបាតបំណុលធៀប ផ.ស.ស. ត្រឹម ២០,៦% (មិនរួមបញ្ចូលបំណុលមរតក) និង ២២,៨% (រួមបញ្ចូលបំណុលមរតក) តាមគោលដៅកំណត់ក្នុងឯកសារយុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងបំណុល ២០១៥-២០១៨ (ទាបជាង ៤០%) ។

បន្ថែមពីនេះ ការកើនឡើងនៃទំហំចំណូល បានផ្តល់លទ្ធភាពឱ្យរាជរដ្ឋាភិបាល បង្កើនចំណាយយ៉ាងច្រើន ទៅលើការលើកកម្ពស់គុណភាព និងការពង្រីកវិសាលភាពនៃសេវាសាធារណៈ ទាំងតាមរយៈចំណាយចរន្តថវិកាជាតិ និងទាំងតាមរយៈចំណាយវិនិយោគសាធារណៈ ដើម្បីធ្វើឱ្យការផ្តល់សេវាសាធារណៈ មានភាពកាន់តែប្រសើរឡើង និងកាន់តែខិតជិតនឹងប្រជាពលរដ្ឋ ដែលជាអ្នកប្រើប្រាស់។ លើមូលដ្ឋាននេះ ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ ចំណាយសរុបថវិការដ្ឋ ត្រូវបានកើនឡើងជិតពីរដង ក្នុងនោះ ចំណាយសរុបរបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានបង្កើនជាងបីដង, ចំណាយសរុបរបស់ក្រសួងសុខាភិបាល ត្រូវបានបង្កើនជិតពីរដងកន្លះ, ចំណាយសរុបរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវបានបង្កើនជិតបីដង ហើយចំណាយវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានក្នុងប្រទេស ត្រូវបានបង្កើនជិតពីរដងកន្លះ ។ មួយវិញទៀត សមាមាត្រនៃចំណូលថវិកាពីប្រភពហិរញ្ញប្បទានក្រៅប្រទេសក្នុងចំណែកថវិកាជាតិ បានថយចុះពីប្រមាណជិត៧០% នៅក្នុងឆ្នាំ១៩៩៥ មកនៅត្រឹមតែប្រមាណ ២១,៥% ប៉ុណ្ណោះក្នុងឆ្នាំ២០១៧ ហើយនឹងបន្តថយចុះថែមទៀត នៅមិនដល់ ២០% នៅឆ្នាំ ២០១៨ ។ ប្រការនេះ គឺជាការសបញ្ជាក់ឱ្យឃើញថា កម្ពុជាកាន់តែមានឯករាជ្យភាពខាងថវិកាជាងមុន និងកាន់តែមានភាពជាម្ចាស់ជាងមុន ។

ទន្ទឹមនេះ ភារកិច្ចនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មិនមែនគ្រាន់តែត្រូវផ្តោតលើការខិតខំប្រមូលចំណូល ដើម្បីបំពេញបង្រប់សេចក្តីត្រូវការចំណាយប៉ុណ្ណោះទេ ប៉ុន្តែ គឺជាការគ្រប់គ្រង និងបែងចែកប្រកបដោយប្រសិទ្ធភាព នូវ

ធនធានដ៏កម្ររបស់ជាតិ ដើម្បីបម្រើឱ្យការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ច ។ ក្នុងន័យនេះ រដ្ឋត្រូវថ្លឹងថ្លែងប្រមូលចំណូល (ដោយដាក់បន្ទុកពន្ធ) នៅក្នុងកម្រិតដែលសេដ្ឋកិច្ចអាចទ្រទ្រង់បាន ដើម្បីបង្កើតបរិយកាសអនុគ្រោះសម្រាប់ការវិនិ-យោគ និងសកម្មភាពធុរកិច្ចផង ហើយទន្ទឹមនេះ ក៏គិតគូរអំពីសមធម៌សង្គម និងការជំរុញកំណើនសេដ្ឋកិច្ចផងដែរ តាមរយៈការសម្រាលបន្ទុកពន្ធដល់ប្រជា-ពលរដ្ឋដែលមានចំណូលទាបផង និងការវិភាជចំណាយប្រកបដោយវិចារណ-ភាព សំដៅទ្រទ្រង់កំណើនសេដ្ឋកិច្ច ដោយធានាឱ្យបាននូវចីរភាពនៃថវិកាជាតិផង ។ ក្រៅពីនេះ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវវិធានការគោលនយោបាយចាំបាច់នានា ជាបន្តបន្ទាប់ ក្នុងគោលដៅដោះស្រាយនូវការលំបាក, ក្តីកង្វល់ និងបំណងប្រាថ្នារបស់ប្រជាជន ដូចជា ការលុបចោលនូវការយកកម្រៃសេវាសា-ធារណៈចាំបាច់មួយចំនួន ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមមាន ការលុបប័ណ្ណបើកបរទោចក្រយានយន្ត, ការលើកលែងពន្ធមធ្យោបាយដឹកជញ្ជូនសម្រាប់ទោចក្រយានយន្ត និងត្រីចក្រយានយន្ត កម្លាំងក្រោម ១៥០ សេសេ, ការលុបកម្រៃសេវាសាធារណៈលើលិខិតបញ្ជាក់កំណើត, លើលិខិតអាពាហ៍ពិពាហ៍ និងលើការផ្តល់អត្តសញ្ញាណប័ណ្ណ, ការបញ្ចុះថ្លៃថាមពលអគ្គិសនី និងទឹកស្អាត, ការលុបចោលរបបពន្ធម៉ៅការ, ការដំឡើងកម្រិតអប្បរមានៃប្រាក់បៀវត្សត្រូវជាប់ពន្ធ, ការលើកលែងពន្ធប្រថាប់ត្រាក្នុងវង្វង់សាច់ញាតិ, ការលុបចោលនូវការបង់ភាស៊ី និងថ្លៃផ្សេងៗ ទៀត ចំពោះការលក់ដូររបស់ប្រជាពលរដ្ឋតាមកញ្ច្រែង, កញ្ជើ, ល្អី, ការអនុញ្ញាតឱ្យអាជីវករដែលមានតូប, រាន, ស្តង់ ឬ កន្លែងលក់ដូរ

ដទៃទៀត ទទួលបានសិទ្ធិកាន់កាប់ប្រើប្រាស់ និងអាស្រ័យផល ហើយអាចផ្ទេរសិទ្ធិនេះបាន, ព្រមទាំងការលុបចោលពន្ធសត្តឃាត និងការគ្រប់គ្រងផ្តាច់មុខនៅក្នុងអាជីវកម្មសត្តឃានដ្ឋាន ជាដើម។ គោលនយោបាយទាំងនេះ បានកំពុងតែផ្តល់ជាគុណប្រយោជន៍ដល់ប្រជាពលរដ្ឋទូទៅ ជាពិសេសអ្នកមានចំណូលទាប រួមទាំងមន្ត្រីរាជការ, កងកម្លាំងប្រដាប់អាវុធ, គ្រូបង្រៀន, គ្រូពេទ្យ និងកម្មករ-និយោជិត ក៏ដូចជាដល់អ្នកប្រកបអាជីវកម្មតូចតាចផងដែរ ។

**២. បុរេលក្ខណៈសំខាន់ៗ ត្រូវបានកសាង និងពង្រឹងបន្ថែម ដើម្បីធានានូវគណនេយ្យភាពហិរញ្ញវត្ថុ**

- ប្លង់គណនេយ្យថ្មីសម្រាប់រដ្ឋាភិបាល និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបានកែសម្រួលឱ្យស្របតាមស្តង់ដារអន្តរជាតិ និងដាក់ឱ្យអនុវត្ត ។
- ចំណាត់ថ្នាក់ទាំង៧ នៃមាតិកាថវិកា ត្រូវបានកែសម្រួល រៀបចំថ្មី និងដាក់ឱ្យអនុវត្ត ។
- លុបបំបាត់មុខងារបេឡានៅរតនាគារទាំងស្រុង ដោយបង្វែរមកប្រើ-ប្រាស់សេវារបស់ធនាគារជាតិនៃកម្ពុជា ។
- ប្រព័ន្ធ FMIS ដំណាក់កាលទី១ ត្រូវបានកសាង និងដាក់ឱ្យអនុវត្តនៅអគ្គនាយកដ្ឋានរតនាគារជាតិ និងរតនាគាររាជធានី ខេត្ត, អគ្គនាយក-ដ្ឋានថវិកា និងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល។ ទន្ទឹមនេះ អគ្គនាយកដ្ឋានរតនាគារជាតិ និងបានបញ្ឈប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានខ្មែរ (Khmer Information Technology-KIT) ទាំងស្រុង និងចាប់ផ្តើមប្រើប្រាស់ប្រព័ន្ធ FMIS ពេញលេញ ។

- មុខងារចំនួន ៦ រួមមាន(១). មុខងារវិភាជន៍ថវិកា, (២). មុខងារគណនីត្រូវសង, (៣). មុខងារគណនីត្រូវទារ, (៤). មុខងារគ្រប់គ្រងសាច់ប្រាក់, (៥). មុខងារទិញ និង (៦). មុខងារសៀវភៅធំ នៃប្រព័ន្ធ FMIS ត្រូវបានដាក់ឱ្យអនុវត្ត ។
- អង្គភាពសវនកម្មផ្ទៃក្នុងត្រូវបាននៅគ្រប់ក្រសួង ស្ថាប័ន ដើម្បីពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងមុខងារសវនកម្មផ្ទៃក្នុង ត្រូវបានពង្រឹងជាលំដាប់ ។
- តម្លាភាពថវិកា ត្រូវបានបង្កើនជាលំដាប់តាមរយៈការផ្សព្វផ្សាយនូវឯកសារសំខាន់ៗ រួមមាន (១). សង្ខេបសំណើថវិកា ដែលបានអនុម័តដោយគណៈរដ្ឋមន្ត្រី, (២). ថវិកាសង្ខេបដែលងាយស្រួលយល់ក្រោយច្បាប់ថវិកាត្រូវបានអនុម័ត, (៣). របាយការណ៍លទ្ធផលនៃការត្រួតពិនិត្យការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ, (៤). ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ, (៥). របាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំឆ្នាំ, (៦). របាយការណ៍សវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ, (៧). ព្រឹត្តបត្រស្ថិតិបំណុលសាធារណៈកម្ពុជា និង (៨). ផែនការលទ្ធកម្ម, សេចក្តីជូនដំណឹងការដេញថ្លៃ, ការប្រគល់កិច្ចសន្យាលទ្ធកម្មនិងរបាយការណ៍ត្រួតពិនិត្យកិច្ចលទ្ធកម្មសាធារណៈតាមក្រោយ ដែលស្ថិតនៅក្រោមសិទ្ធសម្រេចលើស្ថាប័នអនុវត្តលទ្ធកម្ម/អង្គភាពថវិកាប្រចាំឆ្នាំ២០១៦ លើកាវិយបរិច្ឆេទឆ្នាំ២០១៥ ។ តាមរយៈការផ្តល់ព័ត៌មាន

ស្តីពីថវិកានៅគ្រប់វដ្តនៃថវិកាជាសាធារណៈ គឺដើម្បីពង្រឹងប្រសិទ្ធ-ភាព, គណនេយ្យភាព និងតម្លាភាពថវិកា ផងដែរ ។

- ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធការគ្រប់គ្រងថវិកា, លទ្ធកម្ម, ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងមូលបត្ររដ្ឋ ត្រូវបានប្រកាសឱ្យប្រើ និងដាក់ឱ្យអនុវត្ត ។

រហូតមកដល់ពេលនេះ ប្រព័ន្ធ FMIS ត្រូវបានបញ្ចប់អនុវត្តសាកល្បងនៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួចហើយ ហើយកំពុងតែពង្រីកការអនុវត្តសាក-ល្បងទៅដល់ក្រសួង ស្ថាប័ន ជាបន្តបន្ទាប់ ។ ក្នុងពេលអនាគត, ប្រព័ន្ធនេះ នឹងក្លាយជាយន្តការស្នូល ក្នុងការពង្រឹងប្រសិទ្ធភាពថវិកា និងគណនេយ្យភាពហិរញ្ញវត្ថុនៅគ្រប់កម្រិត ទាំងកម្រិតនៃការត្រួតពិនិត្យហិរញ្ញវត្ថុ, កម្រិតនៃការគ្រប់គ្រងសាច់ប្រាក់ និងកម្រិតនៃការអនុវត្តកម្មវិធី ។

**៣. ក្របខ័ណ្ឌថវិកាកម្មវិធី ត្រូវបានរៀបចំ ពង្រឹង និងពង្រីកជាឧបករណ៍ ផ្សារភ្ជាប់ថវិកានឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល**

- ថវិកាកម្មវិធីសាកល្បងពេញលេញ ត្រូវបានអនុវត្ត និងពង្រីកទៅគ្រប់ក្រសួង ស្ថាប័ន
- គ្រប់ក្រសួង ស្ថាប័ន បានរៀបចំរចនាសម្ព័ន្ធគោលនយោបាយ និងផែនការយុទ្ធសាស្ត្រថវិកា ។
- ក្របខ័ណ្ឌគតិយុត្តនៃការរៀបចំ និងអនុវត្តថវិកាកម្មវិធី ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ។

- យន្តការអង្គភាពថវិកា បានជំរុញឱ្យមានតម្លាភាព គណនេយ្យភាព ការផ្ទេរសិទ្ធិអំណាច និងការទទួលខុសត្រូវនិងការចូលរួមខ្ពស់ពីអង្គ-ភាពជំនាញ ក្នុងដំណើរការនៃវដ្តថវិកា ។

តាមរយៈការអនុវត្តថវិកាកម្មវិធីពេញលេញនៅគ្រប់ក្រសួង ស្ថាប័ន ចាប់ពីឆ្នាំ ២០១៨ តទៅទៀត នឹងជួយដល់ក្រសួង ស្ថាប័នធ្វើការរៀបចំថវិកាកាន់តែផ្សារភ្ជាប់ទៅនឹងគោលនយោបាយ ។ នៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះ ការរៀបចំថវិកា និងការចរចាថវិកា ត្រូវបានពង្រឹង និងកែលម្អមួយកម្រិតខ្ពស់ថែមទៀត តាមរយៈការឆ្លុះបញ្ចាំងបានកាន់តែល្អប្រសើរឡើង នូវអាទិភាពសំខាន់ៗ របស់រាជរដ្ឋាភិ-បាល ព្រមទាំងការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្ត ។

## ៤. សមត្ថភាពមន្ត្រីក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានពង្រឹង

- កំណើនប្រសិទ្ធភាពនៃការអនុវត្តថវិកា÷ ការអនុវត្តខិតជិតគោលដៅនៃឥណទានច្បាប់ ។
- ការបណ្តុះបណ្តាលត្រូវបានរៀបចំជាបន្តបន្ទាប់ និងមានលក្ខណៈប្រមូលផ្តុំ (ជំនាញថវិកា, កិច្ចបញ្ជិការគណនេយ្យ, រជ្ជទេយ្យ, លទ្ធកម្ម -ល-) ។
- គុណភាពនៃផែនការយុទ្ធសាស្ត្រថវិកាកើនឡើង និងសំណើគម្រោងថវិកាប្រចាំឆ្នាំ រៀបចំកាន់តែមានគុណភាព ។

## ៥. ការយល់ដឹង និងការចូលរួមអនុវត្តកម្មវិធីកែទម្រង់កើនឡើង

- សិក្ខាសាលាផ្សព្វផ្សាយ ត្រូវបានរៀបចំជូនថ្នាក់ដឹកនាំ មន្ត្រីរាជការដល់កន្លែងនៅគ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ។

- សិក្ខាសាលាផ្សព្វផ្សាយ ត្រូវបានរៀបចំជូនសិស្ស និស្សិត នៅគ្រឹះស្ថានឧត្តមសិក្សា និងដល់យុវជន ។
- ការផ្សព្វផ្សាយសំបូរបែប រួមមាន ព្រឹត្តបត្រប្រចាំឆមាស, ខិត្តបណ្ណ, គេហទំព័រ, បណ្តាញសង្គម, បណ្តាញសារព័ត៌មាន, កិច្ចសម្ភាសន៍វីដេអូជាដើម ។
- កម្រងសម្រង់ពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈត្រូវបានរៀបចំ និងបោះពុម្ពផ្សព្វផ្សាយ ។

**៦. ទិសដៅជាយុទ្ធសាស្ត្រ ត្រូវបានអនុម័ត សម្រាប់ជាប្រទីប និងជាផែនទីគោចរ ក្នុងការបន្តដំណើរទៅមុខ**

- យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី ។

## ៣.២. វឌ្ឍនភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

គ.ហ.ស. បានប្រើប្រាស់ក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពឆ្នាំ២០១១ ដើម្បីធ្វើការវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុដោយប្រើប្រាស់ទិន្នន័យឆ្នាំ២០១៤-២០១៦ ព្រមទាំងបញ្ចូលវឌ្ឍនភាពនៃការអនុវត្ត PFMRP ឆ្នាំ២០១៧ ជាមូលដ្ឋានផងដែរ ។ ការវាយតម្លៃឆ្នាំ២០១៧ នេះ គឺរៀបចំឡើងក្នុងកម្រិតផ្ទៃក្នុងរដ្ឋាភិបាល ដើម្បីធ្វើការវាស់ស្ទង់អំពីភាពខ្លាំង និងភាពខ្សោយនៃប្រព័ន្ធ ដោយធ្វើការប្រៀបធៀបជាមួយលទ្ធផលនៃការវាយតម្លៃ PEFA ឆ្នាំ២០១៥ ដែលប្រើ-ប្រាស់ទិន្នន័យឆ្នាំ២០១១-២០១៣ ។

ក្នុងន័យនេះ សូចនាករសមិទ្ធកម្មចំនួន ៩ បានកើនឡើងពិន្ទុ ក្នុងនោះ រួមមាន PI-2, PI-4, PI-7, PI-9, PI-10, PI-13, PI-14, PI-18 និង PI-19 និងសូចនាករសមិទ្ធកម្មធ្លាក់ពិន្ទុចំនួន ២ រួមមាន PI-3 និង PI-16 ។

បន្ថែមពីនេះ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺទទួលបានសមិទ្ធកម្មល្អ ទាំងការអនុវត្តថវិកា ទាំងការប្រមូលចំណូលក្នុងស្រុក ប៉ុន្តែបំណុលកកស្ទះ គឺនៅមានភាពទន់ខ្សោយនៅឡើយ ដែលទាមទារឱ្យពង្រឹងបន្ថែម ។ ចំណែកឯតម្លាភាពថវិកា និងលទ្ធកម្មសាធារណៈ ត្រូវបានបង្កើនជាលំដាប់ ដែលកត្តានេះគឺបង្កលក្ខណៈងាយស្រួលដល់សាធារណៈជន ក្នុងស្វែងរកពត៌មានថវិកានៅលើគេហទំព័រក្រសួង ស្ថាប័ន ។ ម្យ៉ាងទៀត ច្បាប់ស្តីពីការគ្រប់គ្រងថវិកាប្រចាំឆ្នាំ និងច្បាប់ស្តីពីការទូទាត់ថវិកាប្រចាំឆ្នាំ គឺមានភាពទាន់ពេលវេលាអនុលោមតាមប្រតិទិន នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ ។ ដើម្បីសម្រេចបានជាអតិបរមានូវគោលបំណងគោលនយោបាយ នៃការផ្តល់សេវាសាធារណៈ គឺទាមទារឱ្យមានការគិតគូរបន្ថែមទៀតលើការរៀបចំថវិកាឱ្យផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងធ្វើការវិភាជថវិកាទៅដល់អង្គភាពប្រតិបត្តិផ្ទាល់ ដូចជា សាលារៀន និងមណ្ឌលសុខភាព ជាដើម ។ ជាទិសដៅបន្ត រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្ត **យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥** ព្រមទាំងចាប់ផ្តើមជាបណ្តើរៗ ធ្វើការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខ័ណ្ឌថវិការយៈពេលមធ្យម ដោយកំណត់ពិដានតាមវិស័យ និងក្រសួង ស្ថាប័ន ។ ក្នុងន័យនេះ ការរៀបចំថវិកានឹងចាប់ផ្តើមគិតរយៈពេលដែលកត្តានេះ នឹងធានា និងទប់ទល់នឹងវិបត្តិធ្ងន់ធ្ងរ ដែលនាំឱ្យប៉ះពាល់ការប្រមូល

ចំណូល ព្រមទាំងត្រូវពង្រឹងការរៀបចំផែនការសាច់ប្រាក់ និងរៀបចំផែនការចំណូល-ចំណាយ ។

### រចនាសម្ព័ន្ធសូចនាករសមិទ្ធកម្មរបស់ PEFA ឆ្នាំ២០១១



# បម្រែបម្រួលលទ្ធផលវាយតម្លៃ PEFA ឆ្នាំ២០១៧ ធៀបនឹងលទ្ធផលឆ្នាំ២០១៥

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| ១ | លទ្ធផលនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ÷ ភាពជឿទុកចិត្តនៃថវិកា | | | |
| PI-1 | ចំណាយសរុបធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | A | A | គម្លាតនៃការអនុវត្តចំណាយធៀបនឹងច្បាប់ថវិកា ដែលជាតម្លៃដាច់ខាត គឺ ឆ្នាំ២០១៤ (៩៨,១២%), ឆ្នាំ២០១៥ (៩៩,៣៤%) និងឆ្នាំ២០១៦ (៩៦,៣៨ %) |
| PI-2 | សមាសធាតុចំណាយធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | D+ | B | វិធីសាស្រ្តផ្តល់ពិន្ទុ M1 |
| (១) | កម្រិតនៃការប្រែប្រួលក្នុងសមាសភាពចំណាយ នៅក្នុងរយៈពេលបីឆ្នាំចុងក្រោយដោយមិនគិតបញ្ចូលនូវចំណាយមិនបានគ្រោងទុក | D | B | គម្លាតនៃសមាសធាតុក្នុងការអនុវត្តចំណាយមានលើសពី ៥% ក្នុង រយៈពេល៣ឆ្នាំចុងក្រោយនេះ គឺឆ្នាំ២០១៤ (១៤,៨៧%) ឆ្នាំ២០១៥ (៧,៤៧%) និងឆ្នាំ២០១៦ (៥,១៤%)។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| (២) | ចំនួនជាមធ្យមនៃការចំណាយដែលបានកើតឡើងជាក់ស្តែងក្នុងខ្ទង់ចំណាយដែលមិនបានគ្រោងទុកនៅក្នុងរយៈពេលបីឆ្នាំចុងក្រោយ | B | B | ចំណាយមិនបានគ្រោងទុកជាក់ស្តែងជាមធ្យមសម្រាប់ឆ្នាំ២០១៤, ឆ្នាំ២០១៥ និង២០១៦ ស្មើនឹង ៣នៃច្បាប់ថវិកា។%៥, |
| **PI-3** | **ចំណូលសរុបធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត** | A | B | ចំណូលក្នុងស្រុកសរុបធៀបនឹងច្បាប់ថវិកាក្នុងឆ្នាំ២០១៤ (១១០,៦៩%),២០១៥ (១១១,៥២%) និង ២០១៦ (១០៥,៩០%)។ ការអនុវត្តនេះ គឺស្ថិតចន្លោះ ៩៤%-១១២% សម្រាប់២ឆ្នាំ នៃរយៈពេល៣ ឆ្នាំចុងក្រោយនេះ។ |
| **PI-4** | **សន្និធិបំណុលកកស្ទះនិងការត្រួត-ពិនិត្យតាមដានបំណុលកកស្ទះ** | D+ | C+ | វិធីសាស្ត្រផ្តល់ពិន្ទុ M1 |
| (១) | កម្រិតស្តុកនៃចំណាយដែលនៅជំពាក់ (គិតជាភាគរយនៃចំណាយសរុបជាក់ស្តែងសម្រាប់ឆ្នាំថវិកា | D | B | សន្និធិសរុបនៃបំណុលកកស្ទះ មានទំហំធំតិចជាង ១២% នៃចំណាយសរុប។ ការគណនានេះ គឺបញ្ចូលការប្រាក់ និងការពិន័យលើបំណុលចាស់ ឬ ហៅថាបំណុលកេមរតកជំពាក់ប្រទេសរុស្សី |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| | ដែលពាក់ព័ន្ធ) និងការប្រែប្រួលថ្មីៗ នៅក្នុងស្តុកចំណាយដែលនៅជំពាក់នេះ | | | និងសហរដ្ឋអាមេរិក ដែលនៅសល់ពីសម័យសង្គ្រាម មានចំនួន ២៨០ លានដុល្លារអាមេរិក ស្មើនឹងប្រមាណ ១១៤៣ ពាន់លានរៀល។ ជាទូទៅ ការវាយតម្លៃលើបំណុលកកស្ទះ គឺត្រូវរាប់បញ្ចូលបំណុលទាំងអស់ដែលមិនទាន់ជម្រះ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជា គឺបាននិងកំពុងចរចារលើបំណុលនេះ។ |
| (២) | ទិន្នន័យដែលអាចស្វែងរកបាន សម្រាប់ការត្រួតពិនិត្យតាមដាននៃចំណាយដែលនៅជំពាក់ | C | C | បង្កើត Query ដើម្បីទាញទិន្នន័យពីប្រព័ន្ធ FMIS។ អគ្គនាយកដ្ឋានរតនាគារជាតិធ្វើការត្រួតពិនិត្យជាប្រចាំខែ។ ប៉ុន្តែមុខងារនេះ មិនបំពេញតម្រូវការរបស់អ្នកប្រើប្រាស់នៅឡើយ ដោយមិនមានជាប្រព័ន្ធស្វ័យប្រវត្តិកម្មនោះទេ ហើយការត្រួតពិនិត្យនេះ និងការងារនេះ មិនទាន់ក្លាយជាការងារជាប្រចាំថ្ងៃនៅឡើយ។ ដើម្បីទទួលពិន្ទុខ្ពស់ជាងនេះ GDNT និង FMWG គួរសិក្សានិងរៀបចំមុខងារមួយដែលអាចតាមដានកាលបរិច្ឆេទលើសក្ខីបត្រ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| | | | | ចាប់ថ្ងៃទទួលបានពីអ្នកផ្គត់ផ្គង់ រហូតដល់ថ្ងៃទូទាត់ និងអាចផ្តល់ដំណឹងជូនអ្នកប្រើប្រាស់ ។ |
| ២ | **ការខារត្រួតស៊ីគ្នាសំខាន់ៗ ÷ ភាពគ្រប់ជ្រុងជ្រោយ និងតម្លាភាពនៃថវិកា** | | | |
| PI-5 | ចំណាត់ថ្នាក់ថវិកា | C | C | មាតិកាដែលត្រូវបានប្រើប្រាស់សម្រាប់ការរៀបចំថវិកានិងគណនេយ្យ មានតែចំណាត់ថ្នាក់រដ្ឋបាលនិងចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធី។ បន្ថែមពីនេះ ឆ្នាំ២០១៧ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ឱ្យអនុវត្តប្រកាសស្តីពីចំណាត់ថ្នាក់រដ្ឋបាល, ចំណាត់ថ្នាក់មុខងារ, ចំណាត់ថ្នាក់ភូមិសាស្ត្រ, ចំណាត់ថ្នាក់គម្រោង និងប្រភពមូលនិធិ។ |
| PI-6 | ភាពគ្រប់ជ្រុងជ្រោយនៃពត៌មានដែលត្រូវបានបញ្ចូលនៅក្នុងឯកសារថវិកា | C | C | ឯកសារថវិកាចំនួន ៣ ក្នុងចំណោមឯកសារថវិកាសរុបចំនួន ៩ (១, ៣, ៨) មានក្នុងឯកសារសំណើថវិកា ដែលត្រូវបានបញ្ជូនទៅអង្គនីតិបញ្ញត្តិ ក្នុងឆ្នាំ២០១៥។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| PI-7 | **ទំហំនៃប្រតិបត្តិការរបស់រដ្ឋាភិបាលដែលមិនត្រូវបានរាយការណ៍** | C | C+ | វិធីសាស្ត្រផ្តល់ពិន្ទុ M1 |
| (១) | ចំណាយថវិកាបន្ថែមដែលមិនត្រូវបានរាយការណ៍ | C | A | យោងមាត្រា១៤ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ចែងថា គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវមានថវិកាស្វយ័ត។ ប្រភពធនធានជាប្រចាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលរួមមាន ចំណូលផ្ទាល់ និងចំណូលយថាហេតុ មានការឧបត្ថម្ភតុល្យភាពដោយថវិការដ្ឋ។ រីឯចំណាយជាប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋ-បាល ត្រូវគោរពតាមវិធាននៃចំណាត់ថ្នាក់ និងការគ្រប់គ្រងដូចចំណាយជាប្រចាំរបស់រដ្ឋដែរ។<br>ការកត់ត្រាចំណាយត្រូវបានបញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងស្មើតែគ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាលមានមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនៅប្រចាំការ។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| (២) | ព័ត៌មានស្តីពីចំណូល/ចំណាយ សម្រាប់គម្រោងដែលគាំទ្រដោយហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ | C | C | ច្បាប់ទូទាត់ថវិកា បង្ហាញប្រតិបត្តិការឆ្លងកាត់រតនាគារ និងប្រតិបត្តិការមិនឆ្លងកាត់រតនាគារ ដែលគ្រប់គ្រងដោយអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល។ គម្រោងដោយហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ គឺធ្វើឡើងតាមកម្មវិធីវិនិយោគសាធារណៈ (PIP)។ |
| **PI-8** | **តម្លាភាពនៃទំនាក់ទំនងហិរញ្ញវត្ថុនៅគ្រប់ថ្នាក់នៃរដ្ឋបាល ថ្នាក់ជាតិនិង) (ក្រោមជាតិ** | **B** | **B** | វិធីសាស្ត្រផ្តល់ពិន្ទុ M2 |
| (១) | តម្លាភាព និងភាពមិនលម្អៀងក្នុងការបែងចែកធនធានក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិ | A | A | ឃុំសង្កាត់ ជាទូទៅពឹងផ្អែកទាំងស្រុងលើ ឧបត្ថម្ភធនពីមូលនិធិឃុំ-សង្កាត់។ ការវិភាជ តាមខ្សែបណ្តោយ (**Vertical**) ទៅមូលនិធិនិងការវិភាជតាមខ្សែទទឹង (**Horizontal**) ទៅគ្រប់ឃុំ សង្កាត់ ផ្អែកលើប្រព័ន្ធដែលមានតម្លាភាពនិងមានរូបមន្តច្បាស់លាស់។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| (២) | ភាពទាន់ពេលវេលានៃព័ត៌មានដែលអាចជឿទុកចិត្តបានស្តីពីការវិភាជថវិកា សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ | A | A | ឃុំ សង្កាត់ត្រូវបានផ្តល់ព័ត៌មានអំពីឧបត្ថម្ភកធនដែលនឹងត្រូវទទួលបាន ក្នុងរវាងប៉ុន្មានខែ មុននឹងបញ្ចប់ការរៀបចំថវិការបស់ខ្លួន រីឯការផ្តល់ថវិកាធ្វើឡើងតាមកាលវិភាគច្បាស់លាស់ ដោយមានការពន្យារពេលតែចំពោះ ឃុំ សង្កាត់ណាដែលមិនបានផ្តល់របាយការណ៍ត្រឹមាសទាន់ពេលវេលា។ |
| (៣) | កម្រិតនៃការប្រមូលសរុបទិន្នន័យហិរញ្ញវត្ថុរបស់រដ្ឋាភិបាលដោយអនុលោមតាមយុទ្ធសាស្ត្រតាមវិស័យ | D | D | ក្នុងឆ្នាំ២០១៤-២០១៦ នេះ ចំណាត់ថ្នាក់មុខងារ ឬវិស័យ នៃចំណាយ មិនត្រូវបានបញ្ចូលទាំងក្នុងប្លង់គណនេយ្យរបស់រដ្ឋបាលថ្នាក់ជាតិ និងរបស់រដ្ឋបាលឃុំ សង្កាត់។<br>ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ ការអនុវត្តចំណាត់មុខងារនៅថ្នាក់ក្រោមជាតិ នឹងជំរុញឱ្យប្រសិទ្ធភាពនៃការវិភាគ និងវិភាជន៍។ |
| **PI-9** | **ការត្រួតពិនិត្យហានិភ័យថវិកា ពីអង្គភាពសាធារណៈដទៃទៀតក្រៅពីក្រសួង ស្ថាប័នរដ្ឋ** | C+ | B+ | វិធីសាស្ត្រផ្តល់ពិន្ទុ M1 |

| ល.រ | សូចនាករ | ពិន្ទុឆ្នាំ២០១៥ | ពិន្ទុឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| (១) | កម្រិតនៃការតាមដានរបស់រដ្ឋបាលថ្នាក់កណ្តាលទៅលើអង្គភាពស្វ័យតនិងសហគ្រាសរដ្ឋ | C | B | អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធទទួលបានរបាយការណ៍ប្រចាំឆ្នាំពីគ្រប់សហគ្រាសសាធារណៈនិងភាគច្រើននៃគ្រឹះស្ថានសាធារណៈរដ្ឋបាល។ ការបូកសរុបរួមនៃរបាយការណ៍ថវិកាត្រូវបានរៀបចំ (មិនរាប់បញ្ចូលធនាគារជាតិនៃកម្ពុជា)។ កម្រិតហានិភ័យ គឺនៅមានកម្រិតទាប ដោយសារច្បាប់ប្រព័ន្ធរាល់ការខ្ចី គឺត្រូវមានការអនុញ្ញាតពី កសហវ ។ |
| (២) | កម្រិតនៃការតាមដានរបស់រដ្ឋបាលថ្នាក់ជាតិទៅលើស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | A | A | ស្ថានភាពហិរញ្ញវត្ថុនៅគ្រប់កម្រិតនៃរដ្ឋបាលថ្នាក់ក្រោមជាតិ គឺត្រូវបានតាមដានជាត្រីមាស និងរៀបចំជារបាយការណ៍ដាច់ដោយឡែកពីគ្នា សម្រាប់ថ្នាក់នីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាក់ស្តែង របាយការណ៍នេះមិនបានកំណត់ ឬ វិភាគពីបញ្ហាហានិភ័យហិរញ្ញវត្ថុទេ តាមការអនុវត្ត ឃុំ សង្កាត់មិនអាចបង្កើតជាហានិភ័យទៅលើរដ្ឋបាលថ្នាក់ជាតិបានទេ។ |

| ល.រ | សូចនាករ | ពិន្ទុឆ្នាំ២០១៥ | ពិន្ទុឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| PI-10 | លទ្ធភាពរបស់សាធារណជនក្នុងការទទួលបានព័ត៌មានថវិកាសំខាន់ៗ | D | B | មានលក្ខខណ្ឌចំនួន ៣ ក្នុងចំណោម ៦ ឯកសារត្រូវបានបំពេញ។ ទោះបីជាមានឯកសារចំនួន ២ ឯកសារ គឺត្រូវបានផ្សព្វផ្សាយជាសាធារណៈ ក៏មានការយឺតយ៉ាវក្នុងការផ្សព្វផ្សាយដែរ។ |
| ៣ | **វដ្តថវិកា** | | | |
| ៣.១ | **ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ** | | | |
| PI-11 | កាលានុក្រមនិងការចូលរួមក្នុងកិច្ចដំណើរការរៀបចំថវិកាប្រចាំឆ្នាំ | A | A | វិធីសាស្ត្រផ្តល់ពិន្ទុ M2 |

| ល.រ | សូចនាករ | ពិន្ទុឆ្នាំ២០១៥ | ពិន្ទុឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| (១) | អត្ថិភាព និងការប្រកាន់ខ្ជាប់កាលវិភាគថវិកា | A | A | ក្រសួង-ស្ថាប័នមានរយៈពេល ៤ ទៅ ៥សប្ដាហ៍ ក្នុងមួយដំណាក់-កាល ដើម្បីរៀបចំថវិកាទាំងពីរដំណាក់កាល ពោលគឺសរុបប្រហែល ៩ សប្ដាហ៍។ ដំណាក់កាលទាំង២ មានពិដានថវិកា (ទន់ភ្លន់) ដែលត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី។ ទន្ទឹមនេះមានការពន្យាររយៈពេលខ្លីដោយក្រសួង-ស្ថាប័នមួយចំនួន តែមិនមានអ្វីគួរឱ្យកត់សម្គាល់ទេ និងមិនមានអ្វីប៉ះពាល់ដល់ការអនុវត្តតាមកាលវិភាគឡើយ។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| (២) | ភាពច្បាស់លាស់ភាពគ្រប់ជ្រុង/ ជ្រោយនិងការចូលរួមផ្នែកនយោបាយ ក្នុងការណែនាំអំពីការរៀបចំដាក់សំណើថវិកា | A | A | សារាចរផែនការយុទ្ធសាស្ត្រថវិកា ត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាល ដោយផ្អែកលើការអនុម័តក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងការសើរើ និងការធ្វើអាទិភាវូបនីយកម្មឡើងវិញនូវគោលនយោបាយ។ សារាចររៀបចំកញ្ចប់ថវិកា ត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាល និងផ្ញើជូនគ្រប់ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត។ ការកំណត់ពិដានពីលើចុះក្រោម គឺកំណត់សម្រាប់ចំណាយសរុប (ថវិកាចរន្ត និងថវិកាមូលធន ត្រូវកំណត់ដាច់ពីគ្នា) និងសម្រាប់វិស័យទាំង ៤ (សង្គមកិច្ច សេដ្ឋកិច្ច រដ្ឋបាលទូទៅ និងការពារជាតិ និងសន្តិសុខសាធារណៈ) ជាភាគរយ នៃ ផ.ស.ស (ជាការចង្អុលបង្ហាញ)។ ការរៀបចំគម្រោងថវិកាលម្អិត ដោយក្រសួង ស្ថាប័ន និងរាជធានី ខេត្ត ត្រូវផ្អែកលើ កម្រិតកំណើនធៀបនឹងឆ្នាំចាស់ ដែលអនុញ្ញាតសម្រាប់ចំណាត់ថ្នាក់សេដ្ឋកិច្ចនីមួយៗ។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| (៣) | ការអនុម័តថវិកាទាន់ពេលវេលា ដោយអង្គនីតិប្បញ្ញត្តិ ឬស្ថាប័នមានសមត្ថកិច្ចប្រហាក់ប្រហែល | A | A | ច្បាប់ថវិកាត្រូវបានអនុម័តដោយអង្គនីតិប្បញ្ញត្តិ និងឡាយព្រះហស្ថលេខាដោយព្រះមហាក្សត្រមុនថ្ងៃទី៣១ ខែធ្នូ សម្រាប់ ៣ឆ្នាំសារពើពន្ធចុងក្រោយនេះ |
| **PI-12** | **ទស្សនៈវិស័យច្រើនឆ្នាំក្នុងការធ្វើផែនការថវិកា គោលនយោបាយ ចំណាយនិងការរៀបចំថវិកា** | C+ | C+ | វិធីសាស្ត្រផ្ដល់ពិន្ទុ M2 |
| (១) | ការរៀបចំនូវការព្យាករណ៍ថវិកាពហុឆ្នាំ និងការវិភាជតាមមុខងារ | C | C | ការព្យាករណ៍ថវិកាសរុបរយៈពេល៣ឆ្នាំ ត្រូវបានរៀបចំជារៀងរាល់ឆ្នាំដោយផ្អែកលើសមាសធាតុធំៗ នៃសេដ្ឋកិច្ច។ ប៉ុន្តែមិនមានការញែកចេញជាចំណាត់ថ្នាក់វិស័យ មុខងារ ឬរដ្ឋបាល ហើយបម្រែបម្រួលពីមួយឆ្នាំទៅមួយឆ្នាំទៀតក៏មិនត្រូវបានពន្យល់លម្អិតឡើយ។ |
| (២) | វិសាលភាពនិងភាពញឹកញាប់នៃការវិភាគនិរន្តរភាពបំណុល | A | A | ការវិភាគចីរភាពបំណុលដែលគ្របដណ្ដប់បំណុលបរទេស និងក្នុងស្រុក ត្រូវបានគ្រប់គ្រងនិងពិនិត្យជាប្រចាំឆ្នាំដោយ កសហវ។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| (៣) | យុទ្ធសាស្ត្រតាមវិស័យដែលមានការគណនាចំណាយចរន្តនិងចំណាយវិនិយោគសម្រាប់រយៈពេលច្រើនឆ្នាំ | C | C | វិស័យអប់រំ និងវិស័យសុខាភិបាលបានធ្វើការកំណត់ចំណាយយ៉ាងពេញលេញក្នុងផែនការយុទ្ធសាស្ត្រដោយបានតម្រឹមជាមួយនឹងថវិកាសរុប។ វិស័យទាំងពីរនេះ ស្មើនឹងប្រមាណ ២៤%នៃចំណាយគោលសរុប។ ដោយឡែក សម្រាប់វិស័យផ្សេងទៀតក៏មានផែនការយុទ្ធសាស្ត្រដែរ ប៉ុន្តែមិនមានការព្យាករណ៍ចំណាយច្បាស់លាស់ និងនៅមិនទាន់មានសង្គតិភាព។ |
| ៤)) | ការផ្សារភ្ជាប់គ្នារវាងថវិកាវិនិយោគនិងការព្យាករចំណាយរំកិល | C | C | ការសម្រេចចិត្តវិនិយោគ គឺធ្វើឡើងដោយផ្អែកលើប្រភពធនធានខាងក្រៅច្បាស់លាស់ ជាជាងការយកយុទ្ធសាស្ត្រវិស័យជាមូលដ្ឋាន។ បច្ច័យជាចំណាយចរន្តសម្រាប់អាទិភាពគម្រោងមិនបានដាក់បញ្ចូលធាតុផ្សំសំខាន់សម្រាប់ការជ្រើសរើស និងមានតែនៅក្នុងវិស័យផ្លូវថ្នល់ និងធារាសាស្ត្រ អមដោយថវិកាចរន្តសម្រាប់ប្រតិបត្តិការ និងការថែទាំ។ |
| ៣.២ | **ភាពអាចប៉ាន់ប្រមាណបាន និងការត្រួតពិនិត្យការអនុវត្តថវិកា** | | | |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| PI-13 | **តម្លាភាពនៃកាតព្វកិច្ចជាប់ពន្ធ និង បំណុលពន្ធរបស់អ្នកជាប់ពន្ធ** | C+ | B | វិធីសាស្រ្តផ្តល់ពិន្ទុ M2 |
| (១) | ភាពច្បាស់លាស់ និងភាពគ្រប់ជ្រុងជ្រោយ នៃគោលការណ៍ច្បាប់ និងនីតិវិធីរដ្ឋបាលស្តីពីបំណុលពន្ធ | C | C | យោងសៀវសរឆ្នាំ២០១៧ រៀបចំដោយសភាពាណិជ្ជកម្មសហភាពអឺរ៉ុប គឺលិខិតបដ្ឋានគតិយុត្តិ គឺមានកង្វះខាតនៅឡើយ ដែលទាមទារឱ្យមានការរៀបចំគោលការណ៍ណែនាំ ឬនីតិវិធីលម្អិតលើប្រភេទពន្ធដូចជា អាករតម្លៃបន្ថែម, ពន្ធកាត់ទុក, ពន្ធលើប្រាក់ចំណូល។ល។ រីឯ ពាក់ពន្ធនឹងគយវិញ មមាន ការទូទាត់ផ្លូវការដល់មន្រ្តីគយ សម្រាប់ការបំពេញការងារក្រៅម៉ោងធ្វើការ ជាដើម។<br>ការរៀបចំបំពេញបន្ថែមលិខិតបទដ្ឋានគតិយុត្តនេះ គឺជាឧបករណ៍សំខាន់ ដើម្បីចៀសមន្រ្តីរដ្ឋបាលចំណូលប្រើប្រាស់សិទ្ធិអំណាចរបស់មន្រ្តីរដ្ឋក្នុងការសម្រេច ឬការបកស្រាយភាពមិនច្បាស់លាស់នៃលិខិតបទដ្ឋានគតិយុត្ត។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| (២) | លទ្ធភាពរបស់អ្នកជាប់ពន្ធក្នុងការទទួលបាននូវព័ត៌មានស្តីពីកាតព្វកិច្ចបង់ពន្ធ បំណុលពន្ធ និងនីតិវិធីរដ្ឋបាល | B | B | មានព័ត៌មានជាច្រើន ត្រូវបានផ្សព្វផ្សាយនៅក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងមានវេទិកាដែលជំរុញការជជែកពិភាក្សា រវាងរដ្ឋាភិបាលនិងវិស័យឯកជន។ ចាប់តាំងពីការដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ឆ្នាំ២០១៤-២០១៨ រដ្ឋបាលពន្ធបានបង្កើនគុណភាពការផ្តល់សេវា តាមរយៈការបង្កើតបញ្ជរព័ត៌មាន និងអនុវត្តប្រព័ន្ធព័ត៌មានវិទ្យា, ពង្រឹងរដ្ឋបាលប្រមូលចំណូល, និងការផ្សព្វផ្សាយអំពីកាតព្វកិច្ចរបស់អ្នកជាប់ពន្ធបានយ៉ាងទូលំទូលាយ ផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ការផ្តល់សេវានេះ គឺមិនទាន់មានភាពគ្រប់ជ្រុងជ្រោយនៅឡើយ ប៉ុន្តែការអនុវត្តគឺមានវឌ្ឍនភាពជាលំដាប់។ |
| (៣) | មានដំណើរការនៃយន្តការតវ៉ាពន្ធ | C | B | អនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តក្នុងឆ្នាំ |

| ល.រ | សូចនាករ | ពិន្ទុឆ្នាំ២០១៥ | ពិន្ទុឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| | | | | ២០១៦ ដោយបានបញ្ជាក់យ៉ាងច្បាស់នូវយន្តការ និងនីតិវិធីនៃដោះស្រាយបណ្ដឹង។ |
| **PI-14** | **ប្រសិទ្ធភាពនៃវិធានការសម្រាប់ចុះបញ្ជីអ្នកជាប់ពន្ធ និងការវាយតម្លៃពន្ធ** | **D+** | **C** | វិធីសាស្ត្រផ្ដល់ពិន្ទុ M2 |
| (១) | ការត្រួតពិនិត្យប្រព័ន្ធចុះបញ្ជីអ្នកជាប់ពន្ធ | D | C | ឆ្នាំ២០១៦ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ឱ្យអនុវត្តប្រកាសស្ដីពីការចុះបញ្ជីពន្ធដារ ដើម្បីពង្រឹងការអនុវត្តមាត្រា១១ នៃច្បាប់សារពើពន្ធ។ ប្រកាសនេះ បានកំណត់បុគ្គលទាំងឡាយត្រូវទៅចុះបញ្ជីសារពើពន្ធក្នុងរយៈពេល ១៥ ថ្ងៃ នៃថ្ងៃធ្វើការក្រោយបុគ្គលនោះចាប់ផ្ដើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោយពីពេលទទួលលិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាតចេញដោយក្រសួង ឬ ស្ថាប័នពាក់ព័ន្ធ។ ការស្នើសុំចុះបញ្ជីដោយផ្ទាល់ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| | | | | នៅរដ្ឋបាលសារពើពន្ធ ឬតាមប្រព័ន្ធអេឡិកត្រូនិក (E-registration) ដោយត្រូវបំពេញទម្រង់ចុះបញ្ជីដែលបានកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ។ យោងតាមរបាយការណ៍សវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ អគ្គនាយកដ្ឋានពន្ធដារនៅមានកង្វះចន្លោះក្នុងការប្រមូលព័ត៌មានអំពីសហគ្រាសដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័នមួយចំនួន។ |
| (២) | ប្រសិទ្ធភាពនៃការដាក់ទោសទណ្ឌសម្រាប់ការមិនអនុវត្តតាមកាតព្វកិច្ចចុះបញ្ជីពន្ធ និងការប្រកាសពន្ធ | C | C | នីតិវិធីច្បាប់នៃការដាក់ទោសទណ្ឌសម្រាប់ការមិនអនុវត្តតាមកាតព្វកិច្ចចុះបញ្ជីពន្ធ និងការប្រកាសពន្ធមិនត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពដោយហេតុថា (១) ការផាកពិន័យនៅមានកម្រិតទាប (២) មានបញ្ហាប្រឈមច្រើន ក្នុងការតាមដាន និងការចាប់បង្ខំឱ្យអនុវត្តតាមច្បាប់។ នាពេលបច្ចុប្បន្ន ដើម្បីគ្រប់គ្រងអ្នកជាប់ពន្ធបានបង្កើតប្រព័ន្ធ Auto Printout ដើម្បីព្រីនលិខិតជូនដំណឹងសម្រាប់អ្នកជាប់ពន្ធ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| | | | | ទៅដល់ក្រុមហ៊ុន សហគ្រាសទាំងនោះ ឱ្យមកបំពេញកាតព្វកិច្ចសារពើពន្ធ។<br>នៅឆ្នាំ២០១៦ ទំហំប្រាក់ពិន័យ និងទោសបញ្ញត្តិសារពើពន្ធ ប្រមូលបានចំនួន ៨៤ ៥៩២ ០២៧ ៦៦៥ រៀល (ប្រមាណ ២១ លានដុល្លារអាមេរិក) លើច្បាប់ថវិកាចំនួន ១១៩,៦១%។ |
| (៣) | ការធ្វើផែនការ និងការត្រួតពិនិត្យតាមដានកម្មវិធីសវនកម្មពន្ធ និងកម្មវិធីស៊ើបអង្កេតការគេចវេសពន្ធ | C | C | នៅពេលដែលការអនុវត្តសវនកម្មពន្ធត្រូវបានកែលម្អនឹងពង្រឹងលក្ខណៈវិនិច្ឆ័យវាយតម្លៃហានិភ័យនៃការគេចវេសពន្ធ មិនទាន់ត្រូវបានរៀបចំបានពេញលេញ និងតាមស្តង់ដារ។ លើសពីនេះទៅទៀត វិសាលភាពនៃការអនុវត្តសវនកម្មនៅមានកម្រិត គឺត្រូវបានអនុវត្តទៅលើតែទំនិញនាំចូលនិងនាំចេញ (ចំពោះអគ្គនាយក |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| | | | | ដ្ឋានគយនិងរដ្ឋាករកម្ពុជា) និងគ្របដណ្តប់លើអ្នកជាប់ពន្ធធំតាមរបបពិត តិចតួចប៉ុណ្ណោះ (ចំពោះអគ្គនាយកដ្ឋានពន្ធដារ)។ ដើម្បីពង្រឹងការធ្វើសវនកម្មលើក្រុមហ៊ុន ឬសហគ្រាស, អ.ព.ដ. បាននិងកំពុងរៀបចំសៀវភៅគោលការណ៍ណែនាំសហគ្រាស និងកំពុងជំរុញឱ្យឱ្យអ្នកជាប់ពន្ធតាមវិស័យមួយចំនួនដែលស្ថិតក្រោមគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ គឺតម្រូវឱ្យមានរបាយការណ៍ហិរញ្ញវត្ថុពីស្នងការគណនេយ្យឯករាជ្យ។ |
| PI-15 | **ប្រសិទ្ធភាពនៃការប្រមូលពន្ធ** | D+ | D+ | វិធីសាស្ត្រនៃការផ្តល់ពិន្ទុ M1 |
| (១) | អនុបាតប្រមូលពន្ធចំពោះបំណុលពន្ធដុល ដែលជាភាគរយនៃបំណុលពន្ធនៅដើមឆ្នាំសារពើពន្ធ និងដែលត្រូវបានប្រមូលក្នុងឆ្នាំសារពើពន្ធ | D | D | បំណុលពន្ធសរុបមានទំហំធំ ហើយអនុបាតប្រមូលពន្ធក្នុងឆ្នាំ២០១៤ ដល់ឆ្នាំ២០១៦ ស្ថិតក្រោម ៦០%។ ជាក់ស្តែង លទ្ធផលនៃការប្រមូលបំណុលពន្ធ ធៀបនឹងបំណុលពន្ធសរុប សម្រេច |

| ល.រ | សូចនាករ | ពិន្ទុឆ្នាំ២០១៥ | ពិន្ទុឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| | | | | បាន ៨,៣២% ក្នុងឆ្នាំ២០១៤, ៩,៣៩% នៃឆ្នាំ២០១៥ និង ៨,៩៦% ឆ្នាំ២០១៦) ។ |
| (២) | ប្រសិទ្ធភាពនៃការផ្ទេរប្រាក់ពន្ធដែលប្រមូលបានទៅរតនាគារ ដោយរដ្ឋបាលចំណូល | B | B | ចំណូលភាគច្រើនត្រូវបានផ្ទេរទៅកាន់ រតនាគារជាតិជារៀងរាល់ថ្ងៃ។ ចំណូលពន្ធមួយចំនួនត្រូវបានប្រមូលដោយការិយាល័យគយនិងរដ្ឋាករកម្ពុជា និងសាខាពន្ធដារខេត្ត ខណ្ឌ និងត្រូវបានរក្សាទុកនៅធនាគារ។ ប្រាក់ទាំងនេះមិនត្រូវបានផ្ទេរជារៀងរាល់ថ្ងៃទេ ប៉ុន្តែយ៉ាងហោចណាស់ជារៀងរាល់សប្តាហ៍។ |
| (៣) | ពេលវេលា នៃការផ្ទៀងផ្ទាត់គណនីពេញលេញដោយរតនាគាររវាងការវាយតម្លៃពន្ធ, ការប្រមូលពន្ធ, កំណត់ត្រាបំណុលពន្ធ និង វិក្កយបត្រ | C | C | ពន្ធដែលប្រមូលបានត្រូវបានផ្ទៀងផ្ទាត់ជារៀងរាល់ថ្ងៃ រវាងអគ្គនាយកដ្ឋានរដ្ឋានគារជាតិ និងធនាគារជាតិ។ ប៉ុន្តែការផ្ទួរផ្ទួរតួលេខចំណូលពន្ធរវាងសាខាពន្ធដារ និងរតនាគាររាជធានី ខេត្ត និងសាខាគយនិងរដ្ឋករកម្ពុជា និងរតនាគាររាជធានី ខេត្ត ត្រូវធ្វើជាប្រចាំខែ រីឯការផ្ទួរផ្គងតួលេខថ្នាក់កណ្តាល គឺត្រូវបានធ្វើជាប្រចាំឆ្នាំ។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| PI-16 | **ភាពអាចប៉ាន់ប្រមាណបាននូវអត្ថិភាពថវិកាសម្រាប់ធានាចំណាយ** | C+ | C | វិធីសាស្ត្រផ្តល់ពិន្ទុ M1 |
| (១) | វិសាលភាពដែលលំហូរសាច់ប្រាក់អាចព្យាករណ៍បាន និងត្រូវបានត្រួតពិនិត្យ | B | C | ការព្យាករសាច់ប្រាក់ត្រូវបានធ្វើបច្ចុប្បន្នកម្មប្រចាំត្រីមាស ដោយផ្អែកលើលំហូសាច់ប្រាក់ជាក់ស្តែងត្រីមាសមុន និងព្យាករណ៍ឡើងវិញចំពោះពេលវេលាដែលនៅសល់ក្នុងឆ្នាំ។ ប៉ុន្តែប្រសិទ្ធភាពវិញគឺនៅមានលម្អៀងធំនៅឡើយ និងតួលេខក្រសួង ស្ថាប័នផ្តល់មកគឺនៅមានភាពយឺតយ៉ាវ។ អ្វីជាវឌ្ឍនភាព គឺអគ្គនាយកដ្ឋានរតនាគារជាតិ បានកំពុងដាក់ឱ្យក្រសួង ស្ថាប័ន អនុវត្តប្រព័ន្ធអនឡាញសម្រាប់រៀបចផែនការសាច់ប្រាក់។ |
| (២) | ការជឿទុកចិត្ត និងកំឡុងពេលក្នុងឆ្នាំនៃការផ្តល់ព័ត៌មានថវិកាស្តីពីការកំណត់ពិដានសម្រាប់ការធានាចំណាយ ដល់ក្រសួង ស្ថាប័ន | B | C | ក្រសួង ស្ថាប័ន អាចរៀបចំកម្មវិធីចំណូល និងចំណាយរបស់ខ្លួនជារៀងរាល់ត្រីមាស ប៉ុន្តែក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន គឺមិនទាន់ផ្តល់អាទិភាពលើការអនុវត្តកម្មវិធីចំណូល ចំណាយនៅឡើយ។ ជាការអនុវត្តជាក់ស្តែង ត្រីមាសទី១ |

| ល.រ | សូចនាករ | ពិន្ទុឆ្នាំ២០១៥ | ពិន្ទុឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| | | | | ថវិកាជាតិអនុវត្តបានទាប និងគំហុកចំណាយនៅត្រីមាសទី៤ នៃឆ្នាំ។ |
| (៣) | អត្រានៃការកើតឡើង និងតម្លាភាពនៃការផ្ទេរថវិកាដែលត្រូវបានសម្រេចលើសពីសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន | C | C | ការផ្ទេរថវិកាក្នុងឆ្នាំ មានចំនួនច្រើននិងកើតឡើងច្រើនដង ប៉ុន្តែមានតម្លាភាព ស្របបទប្បញ្ញត្តិយុត្តជាធរមាន។ តាមរយៈការអនុវត្តថវិកាកម្មវិធី ក្រសួង ស្ថាប័នទើបនឹងចូលអនុវត្ត គឺជួបប្រទះបញ្ហាប្រឈមខ្លាំងចំពោះការរៀបចំថវិកាផ្សារភ្ជាប់ទៅនឹងគោលនយោបាយ និងនីតិវិធីការអនុវត្តថវិកាកម្មវិធី។ ជាក់ស្តែង ក្រសួងអប់រំ យុវជន និងកីឡា ធ្វើការនិយ័តថវិកាជាញឹកញាប់ ដោយមួយអង្គភាពថវិកាយ៉ាងហោចណាស់ពី ៣ ទៅ៤ ដងក្នុងឆ្នាំ។ |
| **PI-17** | **ការកត់ត្រានិងការគ្រប់គ្រង សមតុល្យសាច់ប្រាក់, បំណុល និងការធានា** | C+ | C+ | វិធីសាស្រ្តផ្តល់ពិន្ទុ M2 |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| (១) | គុណភាពនៃកំណត់ត្រា និងការរាយការណ៍ទិន្នន័យបំណុល | C | C | កំណត់ត្រាបំណុលក្នុងស្រុក និងក្រៅស្រុក មានភាពពេញលេញ និងត្រូវបានធ្វើបច្ចុប្បន្នកម្ម និងផ្ទៀងផ្ទាត់ជាមួយនឹងរបាយការណ៍ឥណទាយីជារៀងរាល់ឆ្នាំ។<br>ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ គឺធ្វើបច្ចុប្បន្នកម្ម និងផ្ទៀងផ្ទាត់ជាប្រចាំត្រីមាស។ |
| (២) | វិសាលភាពនៃការបូកសរុបសមតុល្យសាច់ប្រាក់របស់រាជរដ្ឋាភិបាល | B | B | តុល្យភាពសាច់ប្រាក់ភាគច្រើនត្រូវបានគណនា និងបូកសរុបយ៉ាងហោចណាស់មួយសប្តាហ៍ម្តង។ |
| (៣) | ប្រព័ន្ធនៃការចុះកិច្ចសន្យាខ្ចី និងការចេញផ្សាយការធានា | C | C | ការចុះកិច្ចសន្យាកម្ចី និងការធានា សុទ្ធសឹងត្រូវបានអនុម័តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្នុងដែនកំណត់សម្រាប់បំណុលសរុប ប៉ុន្តែគោលការណ៍ណែនាំ និងលក្ខខណ្ឌវិនិច្ឆ័យ មិនទាន់ត្រូវបានរៀបចំរួចរាល់នៅឡើយ។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| PI-18 | **ប្រសិទ្ធភាពនៃការត្រួតពិនិត្យបញ្ជីប្រាក់បៀវត្ស** | D+ | C+ | វិធីសាស្ត្រផ្តល់ពិន្ទុ M1 |
| (១) | ការធ្វើសមាហរណកម្ម និងការផ្ទៀងផ្ទាត់រវាងទិន្នន័យចំនួនបុគ្គលិក និងបញ្ជីប្រាក់បៀវត្ស | B | B | គ្មានការភ្ជាប់គ្នាដោយផ្ទាល់រវាងបញ្ជីបុគ្គលិក និងបញ្ជីប្រាក់បៀវត្ស។ ប៉ុន្តែបញ្ជីប្រាក់បៀវត្សប្រចាំខែនីមួយៗ មានភ្ជាប់មកជាមួយឯកសារយោងគ្រប់គ្រាន់ ហើយក្រសួង ស្ថាប័នបានពិនិត្យ និងផ្ទៀងផ្ទាត់ត្រឹមត្រូវ ទៅលើបញ្ជីប្រាក់បៀវត្សប្រចាំខែនីមួយៗ។ |
| (២) | ភាពទាន់ពេលវេលានៃការកែសម្រួលព័ត៌មានបុគ្គលិក និងបញ្ជីប្រាក់បៀវត្ស | C | C | មានការយឺតយ៉ាវរហូតដល់ទៅ ៣ខែ ក្នុងការធ្វើបច្ចុប្បន្នភាពបញ្ជីប្រាក់បៀវត្ស ព្រមទាំងមាននិយ័តកម្មច្រើនលើបញ្ជីទាំងនោះ ។ |
| (៣) | ការត្រួតពិនិត្យផ្ទៃក្នុងទៅលើបម្រែបម្រួលព័ត៌មានបុគ្គលិក និងបញ្ជីប្រាក់បៀវត្ស | B | B | សិទ្ធអំណាចនៃការសម្រេចលើការផ្លាស់ប្តូរស្ថានភាពមន្ត្រី និងបញ្ជីប្រាក់បៀវត្ស មានចែងច្បាស់លាស់ ទោះបីជាគ្មានការធ្វើសវនកម្មទៅលើការអនុវត្តសិទ្ធអំណាចនេះក៏ដោយ។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| (៤) | ការធ្វើសវនកម្មលើបញ្ជីប្រាក់បៀវត្ស ដែលបង្ហាញពីចំណុចខ្សោយនៃការត្រួតពិនិត្យ និង/ឬ ចំនួនមន្ត្រីខ្មោច | D | C | ក្រសួងមុខងារសាធារណៈ បានចុះធ្វើអធិការកិច្ចលើបុគ្គលិក និងបៀវត្សទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេស មន្ត្រីរាជការក្នុងវិស័យអប់រំ។ ករណីបើកបៀវត្សលើសនៅតាមក្រសួង ស្ថាប័ន និងអង្គភាពនានាថ្នាក់ក្រោមជាតិចំនួន ៦១ ករណី និងបានរកឃើញបើកបៀវត្សលើសចំនួន ៣៤១ ១០០ ៦៣៤ រៀល និងបានចាត់វិធានការតាមនីតិវិធីដោយឱ្យបង្វែរថវិកាដែលបើកលើសចូលរតនាគារខេត្តវិញបានរួចរាល់ចំនួន ៧៥ ៧២២ ៦៣០ រៀល ព្រមទាំងធ្វើការតាមដាន និងត្រួតពិនិត្យលើការបង្វែរបៀវត្ស ដែលបើកលើសចូលរតនាគារាជធានី ខេត្ត។ |
| PI-19 | **តម្លាភាព ការប្រកួតប្រជែងនិងយន្ត-ការដោះស្រាយបណ្តឹងតវ៉ាក្នុងកិច្ចលទ្ធកម្ម** | D | C | វិធីសាស្ត្រវាយតម្លៃផ្តល់ពិន្ទុ M2 |

| ល.រ | សូចនាករ | ពិន្ទុឆ្នាំ២០១៥ | ពិន្ទុឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| (១) | មានក្របខ័ណ្ឌគតិយុត្តសម្រាប់ធានាតម្លាភាព ភាពគ្រប់ជ្រុងជ្រោយ និងការប្រកួតប្រជែងក្នុងកិច្ចលទ្ធកម្ម | B | B | ច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ ឆ្លើយតបបានតាម (២០១២) លក្ខខណ្ឌតម្រូវចំនួន ៥ ក្នុងចំណោម ៦។ |
| (២) | ការប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែងក្នុងកិច្ចលទ្ធកម្ម | D | D | នៅឆ្នាំ២០១៦ កិច្ចសន្យាចំនួន ៤៧២ ស្មើនឹង ១ ៤៧៩ ៥៥៤,២១ លានរៀល និងកិច្ចសន្យាតាមប្រភពតែមួយ (Single Source) មានចំនួនកិច្ចសន្យាចំនួន ៣៤២ ស្មើនឹង ១ ៤៥៨ ៩៧៩,៧៨ លានរៀល។ ដូចនេះ ការប្រើប្រាស់វិធីសាស្ត្រតាមប្រភពតែមួយ គឺមានប្រមាណ ៥០% នៃកិច្ចសន្យាសរុប។ ទោះបីជាយ៉ាងណាក៏ដោយ តួលេខបញ្ជាក់ថានៅចំនួនដែលមិនអនុលោមតាមបទប្បញ្ញត្តិ គឺពុំមានការបញ្ជាក់នោះទេ។ |
| (៣) | សាធារណជនអាចទទួលបានព័ត៌មានស្ដីពីកិច្ចលទ្ធកម្មបានគ្រប់ | D | B | អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ បានផ្សព្វផ្សាយផែនការលទ្ធ-កម្ម, ឯកសារដេញថ្លៃ, ការផ្ដល់កិច្ចសន្យា ដែលស្ថិតនៅលើសិទ្ធិ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| | ជ្រុងជ្រោយ ទាន់ពេលវេលា និងអាចទុកចិត្តបាន | | | សម្រេច និងរបាយការណ៍ត្រួតពិនិត្យលទ្ធកម្មតាមក្រោយ នៅលើគេហទំព័រ។ |
| (៤) | មានយន្តការឯករាជ្យសម្រាប់ដោះស្រាយរាល់បណ្តឹងតវ៉ាលើកិច្ចលទ្ធកម្ម | D | D | គ្មានស្ថាប័នឯករាជ្យសម្រាប់ដោះស្រាយបណ្តឹងតវ៉ាលើកិច្ចលទ្ធ-កម្មទេ។ ថ្មីៗនេះ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈបាននិងកំពុងរៀបចំអនុក្រឹត្យស្តីពីយន្តការតវ៉ាបណ្តឹងលទ្ធកម្មសាធារណៈ។ |
| **PI-20** | **ប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងទៅលើចំណាយមិនមែនបៀវត្ស** | C | C | វិធីសាស្ត្រផ្តល់ពិន្ទុ M1 |
| (១) | ប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យនៃការធានាចំណាយ | C | C | គោលការណ៍ណែនាំបានណែនាំតែអំពីនីតិវិធីសម្រាប់ធានាចំណាយចរន្តប៉ុណ្ណោះ។ លើសពីនេះទៅទៀត សំណើធានាចំណាយបន្ទាន់ ឬ សំណើធានាចំណាយពិសេស មិនត្រូវបានអនុវត្តតាមនីតិវិធីទាំងស្រុងទេ។ |
| (២) | ភាពគ្រប់ជ្រុងជ្រោយ ភាពសមស្រប និងការយល់ដឹងពីលិខិតបទដ្ឋាន | C | C | មានគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី ត្រូវបានរៀបចំឡើងសម្រាប់ក្រសួង ស្ថាប័ន ចូលអនុវត្តថវិកាកម្មវិធី។ |

| ល.រ | សូចនាករ | ពិន្ទុឆ្នាំ២០១៥ | ពិន្ទុឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| | គតិយុត្តនិងនីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុង | | | គោលការណ៍ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តនៅថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០១៤។ ដើម្បីឱ្យបានពិន្ទុខ្ពស់ជាងនេះ កសហវ គួរពន្លឿនការរៀបចំមគ្គុទេសក៍គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល ដើម្បីពង្រឹងការអនុវត្តផ្ទៃក្នុង។ |
| (៣) | កម្រិតនៃអនុលោមភាពទៅនឹងវិធាននៃកិច្ចដំណើរការនិងការកត់ត្រាកិច្ចប្រតិបត្តិការ | C | C | ក្រសួង ស្ថាប័នមួយចំនួនធំបានប្រកាន់ភ្ជាប់នូវនីតិវិធី និងវិធានមានជាធរមាន។ ប៉ុន្តែមានក្រសួង ស្ថាប័ន មួយចំនួនមិនទាន់អនុវត្តបាននៅឡើយ។ |
| **PI-21** | **ប្រសិទ្ធភាពនៃសវនកម្មផ្ទៃក្នុង** | **C** | **C** | វិធីសាស្ត្រផ្តល់ពិន្ទុ M1 |
| (១) | វិសាលភាពនិងគុណភាពនៃមុខងាររបស់សវនកម្មផ្ទៃក្នុង | C | C | មុខងារជាសវនកម្មផ្ទៃក្នុង គ្របដណ្តប់ក្រសួង ស្ថាប័ននិងអង្គភាពរបស់រាជរដ្ឋាភិបាលនិងការពិនិត្យជាប្រព័ន្ធ |
| (២) | ភាពទៀងទាត់និងការចែកចាយនៃរបាយការណ៍សវនកម្មផ្ទៃក្នុង | C | C | សវនកម្មផ្ទៃក្នុងដាក់របាយការណ៍ជូនប្រធានស្ថាប័នសាមី និងផ្ញើជូនអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ចនិង |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| | | | | ហិរញ្ញវត្ថុ ប៉ុន្តែការផ្ញើមកអាជ្ញាធរសវនកម្មជាតិនៅមានកម្រិតនៅឡើយ |
| (៣) | ការអនុវត្តទៅតាមអនុសាសន៍ដែលសវនកម្មផ្ទៃក្នុងបានលើកឡើង | C | C | អនុសាសន៍របស់សវនករត្រូវបានយកទៅអនុវត្តតាម នៅក្រសួងស្ថាប័នមួយចំនួនប៉ុណ្ណោះ ពិសេសបញ្ហាប្រឈមចំបង ប៉ុន្តែជាញឹកញាប់មានការពន្យារពេលអនុវត្ត។ |
| **៣.៣** | **គណនេយ្យ, ការកត់ត្រា និងរបាយការណ៍** | | | |
| **PI-22** | **ភាពទាន់ពេលនិងភាពទៀងទាត់នៃការផ្ទៀងផ្ទាត់គណនី** | C | C | វិធីសាស្ត្រដាក់ពិន្ទុ M2 |
| (១) | ភាពទៀងទាត់នៃការផ្ទៀងផ្ទាត់ធនាគារ | B | B | ការផ្ទៀងផ្ទាត់គណនីធនាគារដែលគ្រប់គ្រងដោយរតនាគារជាតិទាំងអស់ត្រូវបានបញ្ចប់ប្រចាំខែនៅក្នុងរយៈពេល ២ សប្តាហ៍។ ប៉ុន្តែគណនីធនាគារចំណាយមិនឆ្លងកាត់រតនាគារត្រូវបានផ្ទៀង-ផ្ទាត់ជាប្រចាំឆ្នាំ។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| (២) | ភាពទៀងទាត់នៃការផ្ទៀងផ្ទាត់និងការទូទាត់គណនីវង់ចាំនិងគណនីបុរេប្រទាន | D | D | ការផ្ទៀងផ្ទាត់និងការទូទាត់នៃគណនីបុរេប្រទានភាគច្រើនចំណាយពេលវេលាយូររហូតដល់ ២ ខែ ដោយសារភាពយឺតយ៉ាវសម្រាប់ការទូទាត់ និងដំណើរការនៃការទូទាត់ដោយសាមីក្រសួងត្រូវចំណាយពេលណាប្រមូលសាក្ខីបត្រហើយធ្វើការបោះផ្សាយអាណត្តិទូទាត់មកវិញរួចបញ្ជូនមករតនាគារជាតិ ដើម្បីទូទាត់បុរេប្រទាន។ |
| PI-23 | **អត្ថិភាពនៃព័ត៌មានស្តីពីធនធានដែលទទួលបានពីអង្គភាពផ្តល់សេវា** | D | D | មិនមានការប្រមូលទិន្នន័យព័ត៌មានគ្រប់ជ្រុងជ្រោយអំពីធនធានដែលទទួលបានដោយសាលាបឋមសិក្សា និងមណ្ឌលសុខភាពនោះទេ។ |
| PI-24 | **គុណភាព និងភាពទាន់ពេលនៃរបាយការណ៍ថវិកាក្នុងឆ្នាំ** | C+ | C+ | វិធីសាស្ត្រដាក់ពិន្ទុ M1 |

| ល.រ | សូចនាករ | ពិន្ទុឆ្នាំ២០១៥ | ពិន្ទុឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| (១) | វិសាលភាពនៃរបាយការណ៍ថវិកាក្នុងឆ្នាំ ក្នុងន័យវិសាលភាពនិងសមិតភាពជាមួយនឹងការព្យាករណ៍ថវិកា | C | C | ការធ្វើចំណាត់ថ្នាក់ទិន្នន័យនៅក្នុងរបាយការណ៍នានា អាចនាំឱ្យការប្រៀបធៀប ធ្វើទៅបានជាមួយថវិកានៃគ្រប់អង្គភាពរដ្ឋបាលសំខាន់ៗ ប៉ុន្តែនៅត្រឹមតែដំណាក់កាលទូទាត់ប៉ុណ្ណោះ។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ គឺត្រូវបញ្ចូលតួលេខនៃធានាចំណាយបន្ថែមទៀត។ |
| (២) | ភាពទាន់ពេលវេលានៃការចេញផ្សាយរបាយការណ៍ | A | A | របាយការណ៍ត្រូវបានរៀបចំប្រចាំខែ និងចេញផ្សាយនៅក្នុងរយៈពេលពី ៤ ទៅ ៨ សប្តាហ៍។ |
| (៣) | គុណភាពនៃព័ត៌មាន | C | C | ចំណាយក្រោមគម្រោងហិរញ្ញប្បទានពីខាងក្រៅ ពុំមានដាក់បញ្ចូលក្នុងរបាយការណ៍ តែបញ្ហាអំពីសុក្រឹតភាព មានតិចតួចប៉ុណ្ណោះ និងមិនប៉ះពាល់ដល់គុណភាពនៃរបាយការណ៍ឡើយ។ បន្ថែមពីនេះ តួលេខពាក់គម្រោងដោយហិរញ្ញប្បទានបរទេស ត្រូវបានធ្វើឡើង ជាប្រចាំឆ្នាំ។ |

| ល.រ | សូចនាករ | ពិន្ទុឆ្នាំ២០១៥ | ពិន្ទុឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| PI-25 | **គុណភាព និងភាពទាន់ពេលវេលានៃរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ** | D+ | D+ | វិធីសាស្ត្រដាក់ពិន្ទុ M1 |
| (១) | ភាពពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុ | D | D | ព័ត៌មានសំខាន់ៗ មិនមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដោយក្នុងនោះរួមមាន ទិន្នន័យសុលបំណុល, ទ្រព្យហិរញ្ញវត្ថុ និងសមតុល្យធនាគារ។ ច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំ គឺបង្ហាញត្រឹមតែសេចក្តីលម្អិតចំណូល និងចំណាយលម្អិត តាមចំណាត់ថ្នាក់សេដ្ឋកិច្ចនិងចំណាត់ថ្នាក់រដ្ឋបាល។ |
| (២) | ភាពទាន់ពេលវេលានៃការបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុ | C | B | របាយការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០១៤, ២០១៥ និង ២០១៦ ត្រូវបានដាក់បញ្ជូនទៅ NAA នៅក្នុងរយៈពេល ១០ ខែបន្ទាប់ពីដំណាច់ឆ្នាំ។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ គឺត្រូវរៀបចំ និងផ្ញើទៅអាជ្ញាធរសវនកម្មជាតិក្នុងរយៈពេល ៦ ខែ បន្ទាប់បញ្ចប់ការិយបរិច្ឆេទនៃការរៀបចំរបាយការណ៍។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| (៣) | បទដ្ឋានគណនេយ្យដែលត្រូវបានប្រើប្រាស់ | C | C | របាយការណ៍នានាត្រូវបានរៀបចំ ដោយមានសង្គតិភាពខ្លះទៅនឹងទម្រង់នៃបទដ្ឋានគណនេយ្យ។ |
| **៣.៤** | **ការត្រួតពិនិត្យ និងសវនកម្មខាងក្រៅ** | | | |
| **PI-26** | **វិសាលភាព ចរិតលក្ខណៈ និង ការតាមដានបន្តនៃសវនកម្មពីខាងក្រៅ** | **NR** | **D+** | វិធីសាស្ត្រវាយតម្លៃ M1 |
| (១) | វិសាលភាព/ ចរិតលក្ខណៈរបស់សវនកម្មដែលត្រូវបានធ្វើឡើង (រួមទាំងការគោរពទៅតាមបទដ្ឋានសវនកម្ម) | NR | D | ការធ្វើសវនកម្មលើចំណាយសរុបមានប្រមាណជាង តិចជាង ៥០% នៃចំណាយសរុប។ |
| (២) | ភាពទាន់ពេលវេលានៃការបញ្ជូនរបាយការណ៍សវនកម្មទៅកាន់សភា | A | A | របាយការណ៍សវនកម្ម ត្រូវបានបញ្ជូនទៅរដ្ឋសភាក្នុងអំឡុងពេល ០៤ ខែ បន្ទាប់ពីទទួលបានរបាយការណ៍ទូទាត់ថវិកា |

| លេ.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| (៣) | ភស្តុតាងនៃការតាមដានបន្តទៅលើអនុសាសន៍សវនកម្ម | C | C | របាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការិយបរិច្ឆេទឆ្នាំ២០១៦ បានបញ្ជាក់ថា អនុសាសន៍កែលម្អចំណុចកង្វះខាត ដែលអាជ្ញាធរសវនកម្មជាតិផ្តល់ជូន អង្គភាពរងសវនកម្មបានយកចិត្តទុកដាក់កែលម្អ ប៉ុន្តែមិនបញ្ជាក់ជាភាគរយការសម្រេចបាននូវអនុសាសន៍ដែលបានលើកឡើងនោះទេ។ |
| PI-27 | **ការត្រួតពិនិត្យលើច្បាប់ថវិកាប្រចាំឆ្នាំដោយអង្គនីតិប្បញ្ញត្តិ** | C+ | C+ | វិធីសាស្ត្រវាយតម្លៃដាក់ពិន្ទុ M1 |

| ល.រ | សូចនាករ | ពិន្ទុឆ្នាំ២០១៥ | ពិន្ទុឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| (១) | វិសាលភាពនៃការត្រួតពិនិត្យរបស់អង្គនីតិបញ្ញត្តិ | C | C | អង្គនីតិបញ្ញត្តិត្រួតពិនិត្យលើសេចក្ដីលម្អិតនៃចំណូល-ចំណាយ នៅដំណាក់កាលដែលសេចក្ដីព្រាងចំណូល-ចំណាយលម្អិត ត្រូវបានរៀបចំបញ្ចប់ដោយរាជរដ្ឋាភិបាលរួចទៅហើយ។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាង អង្គនីតិប្រតិបត្តិ អនុវត្តយុទ្ធសាស្ត្រនៃការកែ-ទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ដោយធ្វើរៀបចំក្របខណ្ឌហិរញ្ញវត្ថុរយៈពេលមធ្យម រួចបញ្ជូនទៅអង្គនីបញ្ញត្តិ ដើម្បីធ្វើការពិនិត្យ។ |
| (២) | កម្រិតនៃការរៀបចំនីតិវិធីបានល្អ និងការអនុវត្តនីតិវិធីបានត្រឹមត្រូវ ក្នុងអង្គនីតិបញ្ញត្តិ | B | B | មាននីតិវិធីសាមញ្ញសម្រាប់ការពិនិត្យនិងអនុម័តដោយអង្គនីតិ-បញ្ញត្តិ អនុលោមតាមច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ គឺត្រូវរៀបចំនីតិវិធីត្រួតពិនិត្យផ្ទៃក្នុងលម្អិត។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| (៣) | ពេលវេលាគ្រប់គ្រាន់សម្រាប់ អង្គនីតិបញ្ញត្តិ ក្នុងការឆ្លើយតបទៅនឹងសំណើថវិកា | C | B | រយៈពេលសម្រាប់ការពិនិត្យ និងអនុម័តដោយ អង្គនីតិបញ្ញត្តិមានប្រមាណ ៧ សប្តាហ៍។ ក្នុងការអនុវត្តជាក់ស្តែង អង្គនីតិ-បញ្ញត្តិ ត្រូវការពេលវេលាតិចជាងនេះសម្រាប់ពិនិត្យនិងអនុម័តសេចក្តីព្រាងច្បាប់ថវិកា។ |
| (៤) | វិធានស្តីពីការកែតម្រូវថវិកាក្នុងឆ្នាំ ដោយពុំចាំបាច់មានការយល់ព្រមជាមុនឬក្រោយពីអង្គនីតិបញ្ញត្តិ | B | B | បទប្បញ្ញត្តិសម្រាប់ការកែសម្រួលឥណទានថវិកានៅក្នុងឆ្នាំអនុវត្តថវិកាដោយពុំចាំបាច់មានការអនុម័តជាមុនពីអង្គនីតិបញ្ញត្តិ ត្រូវបានចែងនិងអនុវត្តតាមច្បាស់លាស់, ព្រមទាំងពុំអនុញ្ញាតឱ្យមានការបង្កើនចំណាយនៅក្នុងឆ្នាំឡើយ ទោះបីជាការប្រមូលចំណូល ) (ទទួលបានលើសពីការចែងក្នុងច្បាប់ក៏ដោយ។ *ជំពូក ៤ ស្តីពីការអនុវត្តថវិកា ត្រង់មាត្រា ៥៥ និងនិងមាត្រា ៦១ នៃច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។*<br>ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ គឺត្រូវកំណត់កម្រិតនៃពិដាននិងប្រកាន់ខ្ជាប់នូវបទប្បញ្ញត្តិជាធរមាន។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| PI-28 | **ការត្រួតពិនិត្យលើរបាយការណ៍សវនកម្មពីខាងក្រៅ ដោយអង្គនីតិប្បញ្ញត្តិ** | B | B | វិធីសាស្ត្រវាយតម្លៃ M1 |
| (១) | ភាពទាន់ពេលវេលានៃការពិនិត្យលើរបាយការណ៍សវនកម្ម ដោយអង្គនីតិប្បញ្ញត្តិ | B | B | របាយការណ៍សវនកម្មត្រូវបានពិនិត្យ ហើយការត្រួតពិនិត្យដោយអង្គនីតិប្បញ្ញត្តិ ត្រូវបានបញ្ចប់ក្នុងរយៈពេល ៣ ខែជាមធ្យម ក្នុងអំឡុងពេលពីរឆ្នាំចុងក្រោយនេះ។ |
| (២) | ការរៀបចំសវនាការដោយអង្គនីតិ-ប្បញ្ញត្តិលើរបកគំហើញគន្លឹះ | B | B | សវនាការលម្អិតត្រូវបានរៀបចំ ដោយមាន ការចូលរួមពីមន្ត្រីពាក់ព័ន្ធនៃអង្គភាពរងសវនកម្ម ប៉ុន្តែពុំត្រូវបានរៀបចំសម្រាប់គ្រប់ស្ថាប័នរងសវនកម្មឡើយ។ |

| ល.រ | សូចនាករ | ពិន្ទុឆ្នាំ២០១៥ | ពិន្ទុឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ |
|---|---|---|---|---|
| (៣) | អនុសាសន៍របស់អង្គនីតិបញ្ញត្តិ និងការអនុវត្តសកម្មភាពអនុលោមតាមអនុសាសន៍ដោយអង្គនីតិប្រតិបត្តិ | B | B | អង្គនីតិបញ្ញត្តិបានផ្តល់អនុសាសន៍ដល់អង្គនីតិប្រតិបត្តិ ហើយអនុសាសន៍មួយចំនួនត្រូវបានអនុវត្តតាម។ |

## ៤. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផលសម្រេចបានខាងលើ ការអនុវត្តកិច្ចការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តែងពើបប្រទះនឹងឧបសគ្គ ព្រមទាំងបញ្ហាប្រឈមនានាជាការធម្មតាចៀសមិនផុត រួមមាន បញ្ហាស្ថាប័ន, បច្ចេកទេស និងធនធានហិរញ្ញវត្ថុ និងហិរញ្ញវត្ថុ ។ រាជរដ្ឋាភិបាល បានប្ដេជ្ញាមោះមុត និងបានប្រកាន់យកអភិក្រម "**រៀនផង ធ្វើផង**" ឬ "**ឆ្លងស្ទឹងស្ទាបស្ទង់ដុំថ្ម**" ដែលមកដល់ពេលនេះទទួលបានលទ្ធផល និងបទពិសោធជាច្រើនគួរឱ្យកត់សម្គាល់ សម្រាប់ជាទុនបន្តដំណើរទៅមុខទៀត។

ក្នុងន័យនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានជួបប្រទះបញ្ហាសំខាន់រួមមាន ជាអាទិ៍÷

### ទី១. កត្តាស្ថាប័ន

១. យន្តការសម្របសម្រួលរួម រវាងអង្គភាពជំនាញពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាមួយក្រសួង ស្ថាប័ន ជាពិសេស ក្នុងការអនុវត្តថវិកា នៅពុំទាន់ប្រមូលផ្ដុំ;

២. ឆន្ទៈ ការយល់ដឹង និងការចូលរួមរបស់ក្រសួង ស្ថាប័ន កើនឡើងជាលំដាប់ ប៉ុន្តែនៅពុំទាន់គ្រប់គ្រាន់ ក្នុងការជំរុញការងារកែទម្រង់ឱ្យកាន់តែមានសន្ទុះ ជាពិសេស កម្រិតថ្នាក់ដឹកនាំជាន់ខ្ពស់;

៣. ពុំទាន់មានផែនការសកម្មភាពសម្រាប់ផ្សារភ្ជាប់ការងារកែទម្រង់ប្រទាក់ក្រឡាទាំង ៣ ។

### ទី២. កត្តាបច្ចេកទេស និងធនធានមនុស្ស

១. ការរៀបចំផែនការសកម្មភាពលម្អិត (GDAP) របស់អង្គភាពក្រោមឱវាទ កសហវ និងក្រសួង ស្ថាប័ន នៅពុំទាន់ឆ្លើយតបនឹងផែនការសកម្មភាពរួមរបស់កម្មវិធីកែទម្រង់;

២. ការបណ្តុះបណ្តាលត្រូវបានរៀបចំជាច្រើនលើក ប៉ុន្តែភាគច្រើនជាការបញ្ជ្រាបការយល់ដឹង ដោយនៅពុំទាន់បានរៀបចំរយៈពេលមធ្យម និងវែង ដែលសំដៅបង្កើនសមត្ថភាពជំនាញរបស់មន្ត្រី ។

### ទី៣. កត្តាហិរញ្ញវត្ថុ

១. ថវិការដ្ឋសម្រាប់គាំទ្រកម្មវិធីកែទម្រង់នៅមានកម្រិត ដោយនៅមានសេចក្តីត្រូវការគាំទ្រពីហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍;

២. ការរៀបចំការឧបត្ថម្ភលើកទឹកចិត្តដល់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួង ស្ថាប័ន នៅកំពុងរៀបចំវិធាន និងនីតិវិធីនៅឡើយ ដើម្បីអាចអនុវត្តក្នុងឆ្នាំ២០១៨ នេះ។

*ទន្ទឹមនេះ មកទល់បច្ចុប្បន្ន ដៃគូអភិវឌ្ឍន៍ រួមមាន សហភាពអឺរ៉ុប, ធនាគារពិភពលោក, ធនាគារអភិវឌ្ឍន៍អាស៊ី និងអង្គការយូនីសេហ្វ បានចូលរួមយ៉ាងសកម្ម ទាំងជាបច្ចេកទេស ទាំងជាហិរញ្ញវត្ថុ។*

## ៥. ទិសដៅរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ

ទិសដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺត្រូវសម្រេចគោលដៅគន្លឹះ ៣ ខាងក្រោម÷

១. បូរណភាពនៃការគោរពវិន័យថវិកា;

២. ប្រសិទ្ធភាពនៃថវិកាទាំងក្នុងផ្នែកវិភាជន៍ ទាំងក្នុងផ្នែកប្រតិបត្តិការ;

៣. ស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

ដើម្បីសម្រេចបានទិសដៅខាងលើ គ្រប់អង្គភាពពាក់ព័ន្ធគ្រប់កម្រិតត្រូវអនុវត្តគោលដៅគន្លឹះ ដូចតទៅ÷

១. ភាពជាម្ចាស់និងភាពជាអ្នកដឹកនាំលើការងារកែទម្រង់គួរតែកំណត់ទុកជាបុរេលក្ខណៈសម្បត្តិសម្រាប់តួនាទីជាថ្នាក់ដឹកនាំនីមួយៗ នៃក្រសួង ស្ថាប័ន;

២. អភិក្រមការងារក្នុងបរិការណ៍កែទម្រង់គួរកែផ្លាស់មកជាបុរេសកម្ម, សកម្មនិងអន្តរសកម្មក្នុងគោលដៅបង្កើត និងបង្កើនកាលានុវត្តភាពអភិវឌ្ឍន៍ថ្មីៗ;

៣. តួអង្គពាក់ព័ន្ធក្នុងការសម្រេចសមិទ្ធកម្មកែទម្រង់គួរត្រូវបានលើកទឹកចិត្តសមស្របផ្នែកហិរញ្ញវត្ថុនិងមិនមែនហិរញ្ញវត្ថុ និងគុណបំណាច់នានា ។

## ៥.១. ទិសដៅនៃ PFMRP សម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១. រៀបចំក្របខ័ណ្ឌគោលនយោបាយពន្ធរយៈពេលមធ្យមឆ្នាំ ២០១៩-២០២៣;

២. អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥;

៣. ពង្រឹង និងពង្រីកការអនុវត្តប្រព័ន្ធ FMIS ស្របតាមផែនការយុទ្ធ-សាស្ត្រដំណាក់កាលទី២;

៤. រៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុរយៈពេលមធ្យម (MTFF) និងក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF);

៥. ធ្វើវិសោធនកម្មច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ ដើម្បីឱ្យស្របតាមបរិបទប្រព័ន្ធថវិកាថ្មី;

៦. បញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ;

៧. រៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិឆ្នាំ ២០១៨-២០២៥;

៨. រៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ ២០១៩-២០២៥;

៩. រៀបចំក្របខ័ណ្ឌវិនិយោគសាធារណៈ និងភាពជាដៃគូរវាងរដ្ឋ និងឯកជន;

១០. រៀបចំផែនទីចង្អុលបង្ហាញផ្លូវគណនេយ្យបង្ករ;

១១. រៀបចំមគ្គុទេសក៍គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរាជរដ្ឋាភិបាល;

១២. រៀបចំមូលនិធិនៃ PFMRP គ្រប់ជ្រុងជ្រោយ និងកសាងសមត្ថភាពធនធានមនុស្សលើវិស័យហិរញ្ញវត្ថុសាធារណៈ ។

## ៥.២. ទិសដៅនៃ PFMRP សម្រាប់ក្រសួង ស្ថាប័ន

ជាទិសដៅសម្រាប់ការចូលរួមក្នុងឆ្នាំ២០១៨-២០២០ ក្រសួង ស្ថាប័ន គួរផ្តោតលើសកម្មភាពអាទិភាព ដូចខាងក្រោម÷

១. ត្រួតពិនិត្យការអនុវត្តថវិកាកម្មវិធីទាំងពាក់កណ្តាលឆ្នាំ ទាំងប្រចាំឆ្នាំ (គោលបំណង ៣១)

២. ពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (គោលបំណង ៣២)

៣. រៀបចំរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ឱ្យស្របតាមថវិកាកម្មវិធី (គោលបំណង ៣៣)

៤. គ្រប់គ្រង និងអនុវត្តការប្រមូលចំណូល (គោលបំណង ១១)

៥. ពង្រឹងការរៀបចំកម្មវិធីចំណូល-ចំណាយ (គោលបំណង ១៤ និង ១១)

៦. ពង្រឹងតម្លាភាពលទ្ធកម្មសាធារណៈ និងតម្លាភាពថវិកា (គោល-បំណង ២៥)

៧. គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (គោលបំណង ២៥)

៨. ចូលរួមអនុវត្តប្រព័ន្ធ FMIS (១). រៀបចំ SOP,(២). ការគ្រប់គ្រង ការផ្លាស់ប្តូរនិង (៣) អង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិ (គោលបំណង ២១)

៩. ពង្រឹងមុខងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច (គោលបំណង ៣៥)

១០. ពង្រឹងសមត្ថភាព និងការផ្សព្វផ្សាយ PFMRP (គោលបំណង ៥១, ៥២ និង ៥៣)។

## ៦. សន្និដ្ឋាន

រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលបានផ្តល់អាទិភាព និងចាត់ទុកភាពរឹងមាំនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាឆ្អឹងខ្នងនៃការអនុវត្តកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាឱ្យសម្រេចបានប្រកបដោយជោគជ័យ និងចីរភាព។ ក្នុងទិសដៅនេះ PFMRP ពិតជាមានសារៈសំខាន់ក្នុងការជំរុញនិងអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ប្រកបដោយ ជវភាព, វិបុលភាព និងបរិយាប័ន្ន ។

ទន្ទឹមនេះ ក្នុងគោលបំណងលើកកម្ពស់ភាពជាម្ចាស់របស់រាជរដ្ឋាភិបាលកម្ពុជាលើកម្មវិធីកែទម្រង់របស់ខ្លួន ក្នុងបរិបទដែលសេដ្ឋកិច្ចកម្ពុជាមានស្ថិរភាពនៃកំណើន និងការថមថយចុះជាបណ្តើរៗ នៃថវិកាជំនួយរបស់ដៃគូអភិវឌ្ឍន៍ គ.ហ.ស. បានផ្តួចផ្តើមរៀបចំមូលនិធិ PFMRP ក្នុងគោលដៅបង្កើតឱ្យមាននូវកញ្ចប់ថវិកាគ្រប់ជ្រុងជ្រោយមួយ ដែលគាំទ្រការអនុវត្ត PFMRP ។

ជារួម តាមរយៈសមិទ្ធផល ៥ឆ្នាំ គ.ហ.ស. មានសុទិដ្ឋិនិយម និងវាយ-តម្លៃជារួមថា (១).ភាពជឿទុកចិត្តនៃថវិកា នៅតែរក្សាបានជាសារវន្ត ប៉ុន្តែទាមទារឱ្យមានការពង្រឹងការព្យាករ និងការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស, (២). ប្រព័ន្ធគណនេយ្យភាពបាននិងកំពុងកសាងតាមរយៈការដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS ដំណាក់កាលទី២ ជាមួយនឹងភាពប្រុងប្រយ័ត្នខ្ពស់, (៣).ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធីជាមូលដ្ឋាន

គ្រឹះសម្រាប់រៀបចំនិងកំណត់ការផ្លាស់ប្តូរប្រព័ន្ធថវិកាកម្ពុជា, (៤). យុទ្ធ-សាស្ត្រ នៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ ជាសមាសធាតុសំខាន់សម្រាប់កំណត់ទិសដៅនៃគណនេយ្យភាពសមិទ្ធកម្ម ដែលជាគោលដៅចុងក្រោយនៃ PFMRP និង (៥). ការរៀបចំប្រព័ន្ធលើកទឹកចិត្តនឹងជំរុញការធ្វើស្ថាប័ននីយកម្ម ឱ្យស្របតាមទិសដៅនៃការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ទន្ទឹមនេះ គ.ហ.ស. ធ្វើការវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទ កសហវ ដែលបានផ្តល់កិច្ចសហការ និងចូលរួមអនុវត្ត PFMRP ជាពិសេស អ.គ.ហ. ដែលបានខិតខំបំពេញមុខងាររបស់ខ្លួនជាឧត្តមសេនាធិការជូន គ.ហ.ស. ទាំងការងារដឹកនាំ, សម្របសម្រួល, គាំទ្រ និងត្រួតពិនិត្យនិងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាំងប្រចាំត្រីមាស និងប្រចាំឆ្នាំ ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងឆ្លុះបញ្ចាំងទាំងសមិទ្ធផលនៃ PFMRP និងលទ្ធផលនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, បញ្ហាប្រឈម និងទិសដៅការងារសម្រាប់ធ្វើបន្ត ៕

# កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) គឺជាកម្មវិធីកែទម្រង់មួយនៃកម្មវិធីកែទម្រង់ស្នូលរបស់រាជរដ្ឋាភិបាល ដែលបានកំណត់ក្នុងយុទ្ធសាស្រ្តចតុកោណ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច, បង្កើតការងារ, ធានាសមធម៌ក្នុងសង្គម និងធានាបាននូវប្រសិទ្ធភាព ។ ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលនៃការអនុវត្ត PFMRP រួមមាន ជាអាទិ៍÷

ទី១)- ការកសាងបានពេញលេញនូវមូលដ្ឋានគ្រឹះនៃភាពជឿទុកចិត្តនៃថវិកា

ទី២)- ការសម្រេចបាននូវយន្តការស្នូលនៃគណនេយ្យភាពហិរញ្ញវត្ថុ

ទី៣)- ការសម្រេចបានជាសារវន្តនូវការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ

ទី៤)- ការកែលម្អបន្ថែមលើការផ្សព្វផ្សាយព័ត៌មានស្តីពីថវិកា

ទី៥)- ការសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ជាមួយនឹងការបែងចែកផលនៃកំណើនប្រកបដោយសមធម៌ ព្រមទាំងរក្សាបានជារួម នូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចរឹងមាំ។

**អគ្គលេខាធិការដ្ឋានគណៈកម្មាធិការ**

**ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**